# លិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺ

## ពាក្យលំនាំ

**អ្នកតែង៖**លិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺមានលក្ខណៈប្លែកពីលិខិតឯទៀតៗ គឺមានលំនាំដូចជាសុន្ទរកថារបស់បណ្ឌិតខាងវិន័យម្នាក់។ អ្នកតែងស្គាល់ព្រះគម្ពីរសម្ពន្ធមេត្រីចាស់យ៉ាងច្បាស់ ហើយពន្យល់តាមរបៀបបណ្ឌិតខាងវិន័យ។ អ្នកខ្លះសន្និដ្ឋានថា លោកប៉ូលជាអ្នកតែងលិខិតនេះ អ្នកខ្លះទៀតសន្និដ្ឋានថា លោកអប៉ូឡូស (កិច្ចការ១៨.២៤-២៨) ជាអ្នកតែង ក៏ប៉ុន្តែយើងពុំដឹងពិតប្រាកដថានរណាបានសរសេរលិខិតនេះទេ ហើយក៏ពុំដឹងថាលិខិតនេះសរសេរផ្ញើទៅគ្រីស្តបរិស័ទណាដែរ។ យើងគ្រាន់តែយល់តាមរយៈលិខិតនេះថា អ្នកតែងចង់ដាស់តឿនគ្រីស្តបរិស័ទជាតិយូដាដែលបានប្រែចិត្តជឿព្រះយេស៊ូគ្រីស្ត។ ក្នុងចំណោមបងប្អូនទាំងនោះប្រហែលជាមានបូជាចារ្យជាច្រើន ដែលធ្លាប់ធ្វើពិធីបុណ្យផ្សេងៗក្នុងព្រះវិហារនៅក្រុងយេរូសាឡឹមកាលពីមុនហើយនៅអាឡោះអាល័យពិធីទាំងនោះដដែល។ មួយវិញទៀត ពួកគេអស់សង្ឃឹមដោយជួបនឹងទុក្ខលំបាកព្រោះត្រូវជនរួមជាតិរបស់ខ្លួនបៀតបៀន។

### គោលសំខាន់ៗ៖

អ្នកតែងលិខិតនេះបានលើកយកគោលគំនិតរបស់សាសនាយូដាមកពន្យល់អំពីឋានៈរបស់ព្រះគ្រីស្តដែលប្រសើរជាងលោកម៉ូសេ ព្រោះព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយប្រសើរជាងមហាបូជាចារ្យឯទៀតៗ ព្រោះព្រះអង្គជាព្រះមហាបូជាចារ្យដែលអាចលោះបាបមនុស្សលោកមួយដងជាសូរេច។ ព្រះយេស៊ូក៏បានបូជាព្រះជន្មទុកជាយញ្ញបូជាប្រសើរជាងយញ្ញបូជាដែលគេថ្វាយក្នុងព្រះវិហារ ព្រោះព្រះអង្គនាំមនុស្សឲ្យចូលទៅជិតព្រះជាម្ចាស់ហើយតែងតាំងសម្ពន្ធមេត្រីថ្មីដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច។

អ្នកតែងលិខិតនេះក៏បានដាស់តឿនគ្រីស្តបរិស័ទឲ្យមានចិត្តតស៊ូស្មោះត្រង់នឹងជំនឿ ដោយលើកយកអ្នកជឿពីជំនាន់ដើមធ្វើជាគំរូ។

### គម្រោងគម្ពីរហេប្រឺ៖

- សេចក្ដីផ្ដើម ១.១-៣
- ព្រះគ្រីស្តប្រសើរជាងពួកទេវទូត ១.៤-២.១៨
- ព្រះគ្រីស្តប្រសើរជាងលោកម៉ូសេ និងលោកយ៉ូស៊ូអា ៣.១-៤.១៣
- ព្រះគ្រីស្តប្រសើរជាងមហាបូជាចារ្យ ៤.១៤-៧.២៨
- ព្រះគ្រីស្តប្រសើរជាងសម្ពន្ធមេត្រី ៨.១-

៩.២៨
•ព្រះគ្រីស្តប្រសើរជាងយញ្ញបូជា ១០.១-៣៩
•អំពីជំនឿ ១១.១
-១២.២៩
•ជីវិតស្របតាមព្រះជាម្ចាស់ ១៣.១
-១៩
•អវសានថា ១៣.២០-២៥

លិខិតផ្ញើជូន
គ្រីស្តបរិស័ទជាតិហេប្រឺ

## សេចក្តីផ្តើម

១នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូល
១មកកាន់បុព្វបុរស*យើង ជាច្រើនលើកច្រើន
សា ដោយប្រើរបៀបផ្សេងៗជាច្រើនតាមរយៈ
ពួកព្យាការី*។ ២គ្រានេះជាគ្រាចុងក្រោយបំផុត
ព្រះអង្គមានព្រះបន្ទូលមកយើងតាមរយៈព្រះ
បុត្រា។ ព្រះអង្គបានប្រគល់អ្វីៗទាំងអស់ឲ្យព្រះ
បុត្រាគ្រប់គ្រងជាមត៌ក ព្រះអង្គក៏បានបង្កើត
ពិភពទាំងមូល ដោយសារព្រះបុត្រាដែរ។ ៣
ព្រះបុត្រានេះជារស្មីនៃសិរីរុងរឿងរបស់ព្រះជា
ម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ។
ព្រះបុត្រាទ្រទ្រង់អ្វីៗទាំងអស់ដោយសារព្រះ
បន្ទូលប្រកបដោយឫទ្ធានុភាព។ លុះព្រះអង្គ
ប្រោសមនុស្សឲ្យបានបរិសុទ្ធ* ផុតពីបាប*រួច
ហើយ ទ្រង់ក៏គង់នៅខាងស្ដាំព្រះដ៏ឧត្ដុង្គឧត្ដម
នាស្ថានដ៏ខ្ពង់ខ្ពស់បំផុត។ ៤ព្រះបុត្រាបាន
ទទួលព្រះនាម[ក]ប្រសើរ លើសពួកទេវទូត*
យ៉ាងណា ទ្រង់ក៏ទទួលឋានៈប្រសើរជាងពួក
ទេវទូតយ៉ាងនោះដែរ។

## ព្រះយេស៊ូគ្រីស្ដមានឋានៈធំជាងពួកទេវទូត

៥ព្រះជាម្ចាស់ពុំដែលមានព្រះបន្ទូលទៅ
កាន់ទេវទូតណាថា៖

*«ព្រះអង្គជាបុត្ររបស់យើង*
*គឺយើងហ្នឹងហើយដែលបានទទួលព្រះអង្គ*
*ធ្វើជាបុត្រនៅថ្ងៃនេះ»*[ខ]
*ឬមានព្រះបន្ទូលថា៖*
*«យើងនឹងធ្វើជាបិតារបស់ព្រះអង្គ*
*ហើយព្រះអង្គនឹងទៅជាបុត្រារបស់យើង»*[គ]
*សោះឡើយ។*

៦មួយវិញទៀត នៅពេលព្រះជាម្ចាស់ចាត់
បុត្រច្បងឲ្យមកផែនដីនេះទ្រង់មានព្រះបន្ទូល
ថា៖

*«ទេវទូត* ទាំងអស់របស់ព្រះជាម្ចាស់*
*ត្រូវក្រាបថ្វាយបង្គំព្រះបុត្រា»*[ឃ]។

៧ព្រះជាម្ចាស់មានព្រះបន្ទូលអំពីពួកទេវទូត
ថា៖

*«ព្រះអង្គបានយកពួកទេវទូតធ្វើជាខ្យល់*
*និង យកពួកអ្នកបម្រើរបស់ព្រះអង្គ*
*ធ្វើជាអណ្ដាតភ្លើង»*[ង]។

៨ចំពោះព្រះបុត្រាវិញព្រះជាម្ចាស់មានព្រះ
បន្ទូលថា៖

*«បពិត្រព្រះជាម្ចាស់ បល្ល័ង្ករបស់ព្រះអង្គ*
*នៅស្ថិតស្ថេរអស់កល្បជានិច្ច*
*ហើយព្រះអង្គគ្រងរាជ្យដោយយុត្តិធម៌»*[ច]។
៩ *ព្រះអង្គសព្វព្រះហឫទ័យតែនឹង*
*សេចក្ដីសុចរិត*
*ទ្រង់មិនសព្វព្រះហឫទ័យ*
*នឹងអំពើទុច្ចរិតទេ។*
*ហេតុនេះព្រះជាម្ចាស់ជាព្រះរបស់ព្រះអង្គ*
*បានចាក់ប្រេងអភិសេកព្រះអង្គ*

*ឲ្យមានអំណរសប្បាយដ៏លើសលប់*
*គឺឲ្យព្រះអង្គបានប្រសើរជាង*
*មិត្តភក្ដិរបស់ព្រះអង្គ»*[ឆ] ។
១០ ព្រះជាម្ចាស់មានព្រះបន្ទូលទៀតថា៖
*បពិត្រព្រះអម្ចាស់! ព្រះអង្គបានបង្កើតផែនដី*
*តាំងពីដើមដំបូងមកម្ល៉េះ*
*ហើយផ្ទៃមេឃក៏ជាស្នាព្រះហស្ដរបស់*
*ព្រះអង្គដែរ។*
១១ *ផែនដី និង ផ្ទៃមេឃមុខជារលាយបាត់ទៅតែ*
*ព្រះអង្គនៅស្ថិតស្ថេររហូត។*
*ផែនដី និង ផ្ទៃមេឃមុខជាចាស់ទៅ*
*ដូចសម្លៀកបំពាក់*
១២ *ព្រះអង្គនឹងបត់ទាំងផែនដីទាំងផ្ទៃមេឃទុក*
*ដូចគេបត់អាវធំ*
*ផែនដី និង ផ្ទៃមេឃនឹងរេចរឹលទៅ*
*ដូចសម្លៀកបំពាក់*
*ចំពោះព្រះអង្គវិញ ទ្រង់មិនប្រែប្រួលឡើយ*
*ហើយព្រះជន្មាយុរបស់ព្រះអង្គ*
*ក៏មិនចេះអស់ដែរ*[ជ] ។
១៣ មួយវិញទៀតព្រះជាម្ចាស់ក៏មិនដែល
មានព្រះបន្ទូលទៅកាន់ទេវទូតណាថា៖
*«សូមគង់នៅខាងស្ដាំយើង ទម្រាំដល់យើង*
*បង្ក្រាបខ្មាំងសត្រូវរបស់ព្រះអង្គ មកដាក់*
*ក្រោមព្រះបាទារបស់ព្រះអង្គ»*[ឈ] ។
១៤ ទេវទូតទាំងនោះសុទ្ធតែជាវិញ្ញាណដែល
នៅបម្រើព្រះជាម្ចាស់។ព្រះអង្គចាត់ពួកលោក
ឲ្យមកបំពេញមុខងារជាប្រយោជន៍ដល់អស់អ្នក
ដែលត្រូវទទួលការសង្គ្រោះទុកជាមត៌ក!

## ការសង្គ្រោះដ៏ថ្លៃវិសេស

១ ហេតុនេះហើយ បានជាយើងត្រូវយកចិត្ត
ទុកដាក់ នឹងសេចក្ដីប្រៀនប្រដៅដែលយើង
បានស្ដាប់ឲ្យមែនទែន ក្រែងលោ យើងត្រូវ
រសាត់បាត់ទៅ។ ២ ប្រសិនបើព្រះ បន្ទូលដែល
ពួកទេវទូតថ្លែងប្រាប់ យកជាការបាន ហើយបើ
អ្នកដែលប្រព្រឹត្តល្មើសនិងមិនស្ដាប់តាម បាន
ទទួលទោសយ៉ាងហ្នឹងទៅហើយ ៣ ចុះចំណង់
បើយើងវិញ ធ្វើម្ដេចនឹងឲ្យរួចខ្លួនបាន បើយើង
ធ្វេសប្រហែសនឹងការសង្គ្រោះដ៏ថ្លៃវិសេសនេះ?
ជាបឋមព្រះអម្ចាស់បានថ្លែងអំពីការសង្គ្រោះ
ហើយអស់អ្នកដែលបានស្ដាប់ក៏បញ្ជាក់ប្រាប់
យើងដែរ។ ៤ ព្រះជាម្ចាស់ផ្ដល់សក្ខីភាពរួម
ជាមួយពួកគេ ដោយសម្តែងទីសម្គាល់ឫទ្ធិ
បាដិហារិយ៍ ការអស្ចារ្យគ្រប់យ៉ាង ព្រមទាំង
ចែកព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏
វិសុទ្ធ*មក ស្របតាមព្រះហឫទ័យព្រះអង្គផ
ង។
៥ ព្រះជាម្ចាស់ពុំបានប្រគល់ឲ្យពួកទេវទូត*
ត្រួតត្រាពិភពលោកខាងមុខ ដូចយើងធ្លាប់
និយាយនោះទេ។ ៦ ផ្ទុយទៅវិញមានម្នាក់បាន
ផ្ដល់សក្ខីភាពនៅក្នុងវគ្គមួយដែលចែងថា៖
*«តើមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹក*
*ដល់គេដូច្នេះ*
*តើបុត្រមនុស្សជាអ្វីដែរបានជាព្រះអង្គយក*
*ព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ»?*
៧ *«ព្រះអង្គបានធ្វើឲ្យគេមានឋានៈទាបជាង*
*ទេវទូតតែមួយរយៈប៉ុណ្ណោះ*

*ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់*
*គេ ទុកជាមកុដរាជ្យ»*[ញ]
៨ *ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឲ្យ*
*នៅក្រោមជើងរបស់គេ»*[ដ] ។
ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឥត
ទុកឲ្យមានអ្វីមួយនៅសល់ ដែលពុំបានចុះចូល
នោះឡើយ។ ក៏ប៉ុន្តែនៅពេលនេះយើងពុំឃើញ
ថាអ្វីៗសព្វសារពើ សុទ្ធតែបានចុះចូលនឹង
អំណាចរបស់មនុស្សហើយនោះទេ ៩តែយើង
ឃើញថា ព្រះយេស៊ូដែលមានឋានៈទាបជាង
ពួកទេវទូតមួយរយៈ ព្រោះទ្រង់បានរងទុក្ខនិង
សោយទិវង្គតនោះ ឥឡូវនេះព្រះអង្គទទួលសិរី
រុងរឿងនិងព្រះកិត្តិនាម ទុកជាមកុដរាជ្យ។
ដោយសារព្រះហឫទ័យប្រណីសន្ដោស របស់
ព្រះជាម្ចាស់ ព្រះគ្រីស្ដបានសោយទិវង្គត
សម្រាប់មនុស្សគ្រប់ៗរូប។ ១០អ្វីៗទាំងអស់
មានជីវិតដោយសារព្រះជាម្ចាស់ និងសម្រាប់
ព្រះអង្គ ទ្រង់សព្វព្រះហឫទ័យនឹងនាំបុត្រធីតា
ជាច្រើន ឲ្យទទួលសិរីរុងរឿងដូច្នេះគួរគប្បីព្រះ
អង្គប្រោសប្រទានឲ្យម្ចាស់នៃការសង្គ្រោះ[ប]
បានគ្រប់លក្ខណៈដោយរងទុក្ខលំបាក។

១១ព្រះយេស៊ូ ដែលប្រោសមនុស្សឲ្យបាន
វិសុទ្ធ* និងមនុស្សដែលព្រះអង្គប្រោសឲ្យបាន
វិសុទ្ធនោះចេញមកពីប្រភពតែមួយ។ ហេតុនេះ
ហើយបានជាព្រះយេស៊ូមិនខ្មាស នឹងហៅគេថា
ជាបងប្អូនរបស់ព្រះអង្គឡើយ ១២គឺព្រះអង្គមាន
ព្រះបន្ទូលថា៖
*«ទូលបង្គំនឹងផ្សាយដំណឹងអំពីព្រះនាម*
*របស់ព្រះអង្គឲ្យបងប្អូនទូលបង្គំស្គាល់*
*ទូលបង្គំនឹងច្រៀងលើកតម្កើងព្រះអង្គ*
*នៅក្នុងអង្គប្រជុំ»*[ឌ] ។
១៣ *ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖*
*«ទូលបង្គំទុកចិត្តលើព្រះអង្គ» ឈ*
*ហើយថា «ខ្ញុំនៅឯនេះរួមជាមួយ នឹង កូនចៅ*
*ដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំ»*[ណ] ។
១៤ដោយកូនចៅនោះ ជាប់សាច់ឈាម
ជាមួយគ្នាព្រះអង្គក៏បានយកឋានៈជាមនុស្សរួម
ជាមួយគេដែរហើយព្រះអង្គសោយទិវង្គតដើម្បី
កម្ទេចមារ*ដែលមានអំណាចលើសេចក្ដីស្លាប់
១៥និងដើម្បីរំដោះអស់អ្នកដែលជាប់ជាទាសករ
មួយជីវិត ព្រោះតែខ្លាចស្លាប់។ ១៦ព្រះយេស៊ូ
ពិតជាពុំបានយាងមកជួយពួកទេវទូត*ទេគឺព្រះ
អង្គមកជួយពូជពង្ស របស់លោកអប្រាហាំវិញ។
១៧ហេតុនេះហើយបានជាព្រះអង្គត្រូវតែមាន
លក្ខណៈ ដូចបងប្អូនរបស់ព្រះអង្គគ្រប់ជំពូក
ទាំងអស់ ដើម្បីធ្វើជាមហាបូជាចារ្យ*ដែលមាន
ចិត្តមេត្តាករុណា មានចិត្តស្មោះត្រង់ក្នុងការ
បម្រើព្រះជាម្ចាស់ និងដើម្បីរំដោះប្រជាជនឲ្យ
រួចផុតពីបាប*ផង។ ១៨ដោយព្រះអង្គផ្ទាល់បាន
រងទុក្ខលំបាក នៅពេលជួបការល្បួងលព្រះអង្គ
ក៏អាចជួយអស់អ្នក ដែលជួបនឹងការល្បួងល
បានដែរ។

## ព្រះយេស៊ូមានឋានៈធំជាងលោកម៉ូសេ

១បងប្អូនដ៏វិសុទ្ធ*អើយ ព្រះជាម្ចាស់ក៏បាន
៣ត្រាស់ហៅបងប្អូនដែរ! ចូរគិតពិចារណា
មើលអំពីព្រះយេស៊ូ ជាទូតដែលព្រះជាម្ចាស់
បានចាត់ឲ្យមក និងជាមហាបូជាចារ្យ* ដែល
នាំឲ្យយើងមានជំនឿដូចយើងប្រកាស[ត]នោះ
ទៅ។ ២ព្រះយេស៊ូមានព្រះហឫទ័យស្មោះត្រង់
ចំពោះព្រះជាម្ចាស់ដែលបានតែងតាំងព្រះអង្គ
ដូចលោកម៉ូសេមានចិត្តស្មោះត្រង់ ចំពោះកិច្ច
ការក្នុងព្រះដំណាក់ដែរ។ ៣អ្នកសង់ផ្ទះមានកិត្តិ
យស ប្រសើរលើសផ្ទះយ៉ាងណា ព្រះយេស៊ូក៏
គួរនឹងទទួលសិរីរុងរឿងប្រសើរលើសលោកម៉ូ
សេយ៉ាងនោះដែរ ៤ដ្បិតផ្ទះទាំងឡាយសុទ្ធតែ
មានគេបានសង់ឡើង រីឯព្រះជាម្ចាស់វិញ ព្រះ
អង្គបានសង់គ្រប់អ្វីៗទាំងអស់។ ៥ចំពោះលោក
ម៉ូសេ លោកមានចិត្តស្មោះត្រង់នឹងកិច្ចការ ក្នុង
ព្រះដំណាក់ទាំងមូលក្នុងឋានៈលោកជាអ្នក
បម្រើដើម្បីផ្ដល់សក្ខីភាពពីព្រះបន្ទូលដែលព្រះ
ជាម្ចាស់នឹងថ្លែង។ ៦រីឯព្រះគ្រីស្ដវិញ ព្រះអង្គ
មានព្រះហឫទ័យស្មោះត្រង់ក្នុងឋានៈជាព្រះ
បុត្រា ដែលគ្រប់គ្រងលើព្រះដំណាក់ផ្ទាល់របស់
ព្រះអង្គ គឺយើងទាំងអស់គ្នាហ្នឹងហើយ ជាព្រះ
ដំណាក់របស់ព្រះអង្គ ប្រសិនបើយើងនៅកាន់
ចិត្តរឹងប៉ឹង និងពឹងផ្អែក[ថ]លើសេចក្ដីសង្ឃឹមរបស់
យើង[ទ] ជាប់ជានិច្ចមែននោះ។

៧ហេតុនេះដូចព្រះវិញ្ញាណដ៏វិសុទ្ធ*មាន
ព្រះបន្ទូលថា៖

*«ថ្ងៃនេះប្រសិនបើអ្នករាល់គ្នាឮ*
*ព្រះសូរសៀងរបស់ព្រះអង្គ*
៨ *មិនត្រូវមានចិត្តរឹងរូសដូចនៅគ្រាបះបោរ*
*ក្នុងថ្ងៃដែលគេល្បងលព្រះអង្គ*
*នៅវាលរហោស្ថាននោះឡើយ*
៩ *បុព្វបុរសរបស់អ្នករាល់គ្នាបានល្បងលយើង*
*ដើម្បីសាកមើលយើង*
*ហើយគេឃើញកិច្ចការដែលយើងបានធ្វើ*
*ក្នុងអំឡុងពេលសែសិបឆ្នាំ។*
១០ *ហេតុនេះហើយបានជាយើងទាស់ចិត្តនឹង*
*មនុស្សនៅជំនាន់នោះណាស់*
*ហើយយើងបានពោលថា៖*
*ចិត្តរបស់ពួកគេចេះតែវង្វេងរហូតទៅ*
*គេពុំស្គាល់មាគ៌ារបស់យើងឡើយ*
១១ *យើងខឹងនឹងពួកគេ ហើយប្ដេជ្ញា*[ធ] *ថា*
*មិនឲ្យពួកគេចូលមកសម្រាក*
*ជាមួយយើងជាដាច់ខាត»*[ន] *។*

១២ដូច្នេះបងប្អូនអើយ ចូរប្រយ័ត្នក្រែងលោ
នរណាម្នាក់ក្នុងចំណោមបងប្អូន បែរជាមានចិត្ត
អាក្រក់លែងជឿ រហូតដល់ទៅងាកចេញពីព្រះ
ជាម្ចាស់ដ៏មានព្រះជន្មរស់។១៣ផ្ទុយទៅវិញ ចូរ
ដាស់តឿនគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ គឺ
គ្រប់ពេលដែលមានចែងក្នុងគម្ពីរថា «ថ្ងៃនេះ!»
នៅឡើយ ដើម្បីកុំឲ្យបងប្អូនណាម្នាក់ប្រកាន់
ចិត្តរឹងរូសដោយចាញ់បោកបាប*។ ១៤ប្រសិន
បើយើងរក្សាជំហររឹងប៉ឹង ដែលយើងមានតាំងពី
ដំបូងមករហូតដល់ចុងបញ្ចប់មែននោះ យើង
បានចូលរួមជាមួយព្រះគ្រីស្ដហើយ ១៥ព្រោះ

ក្នុងគម្ពីរមានចែងថា៖

*«ថ្ងៃនេះប្រសិនបើអ្នករាល់គ្នាឮ
ព្រះសូរសៀងរបស់ព្រះអង្គ
មិនត្រូវមានចិត្តរឹងរូសដូចនៅគ្រាបះបោរ
នោះឡើយ»។*

១៦តើនរណាខ្លះ បានឮព្រះសូរសៀងរបស់
ព្រះជាម្ចាស់ ហើយបែរជានាំគ្នាបះបោរ?
អស់អ្នកដែលលោកម៉ូសេបាននាំ ចេញពីស្រុក
អេស៊ីបមកនោះឬ? ១៧ក្នុងអំឡុងពេលសែសិប
ឆ្នាំនោះ តើព្រះជាម្ចាស់ទ្រង់ព្រះពិរោធនឹង
នរណាខ្លះ? ព្រះអង្គទ្រង់ព្រះពិរោធនឹងអស់អ្នក
ដែលបានប្រព្រឹត្តអំពើបាប ហើយត្រូវស្លាប់
ចោលឆ្អឹងនៅវាលរហោស្ថាននោះឬ? ១៨តើព្រះ
អង្គបានប្ដេជ្ញាថាមិនឲ្យនរណាខ្លះចូលមក
សម្រាកជាមួយព្រះអង្គ? គឺអស់អ្នកដែលមិន
ព្រមស្ដាប់បង្គាប់ព្រះអង្គនោះឬ? ១៩ដូច្នេះយើង
ឃើញថាពួកគេពុំបានចូលទៅសម្រាក មកពី
ពួកគេគ្មានជំនឿ។

៤ ១ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែល
ថាឲ្យយើងចូលទៅសម្រាកជាមួយព្រះអង្គនោះ
នៅស្ថិតស្ថេរនៅឡើយដូច្នេះ យើងត្រូវភ័យខ្លាច
ក្រែងលោមានបងប្អូនណាម្នាក់នឹកស្មានថា ខ្លួន
ចូលទៅមិនទាន់ ២ដ្បិតយើងក៏បានទទួល
ដំណឹងល្អ*ដូចពួកគេដែរ[ប]។ ក៏ប៉ុន្តែព្រះបន្ទូល
ដែលគេស្ដាប់គ្មានប្រយោជន៍អ្វីដល់គេទេ ព្រោះ
ព្រះបន្ទូលដែលគេបានឮនោះពុំបានជ្រួតជ្រាប
ចូលក្នុងចិត្តគេដោយជំនឿឡើយ។ ៣ព្រះជា
ម្ចាស់មានព្រះបន្ទូលថា «យើងខឹងនឹងពួកគេ
ហើយប្ដេជ្ញាថា មិនឲ្យពួកគេចូលមកសម្រាក
ជាមួយយើងជាដាច់ខាត»។ ចំពោះយើងជាអ្នក
ជឿវិញ យើងបានចូលមកសម្រាកជាមួយព្រះ
អង្គហើយ។

ពិតមែនហើយ ព្រះជាម្ចាស់បានបង្ហើយកិច្ច
ការរបស់ព្រះអង្គ តាំងពីកំណើតពិភពលោកមក
ម្ល៉េះ ៤ដ្បិតមានចែងទុកត្រង់វគ្គមួយស្ដីអំពីថ្ងៃទី
ប្រាំពីរថា៖ ព្រះជាម្ចាស់បង្ហើយកិច្ចការទាំងអស់
នៅថ្ងៃទីប្រាំពីររួចព្រះអង្គក៏សម្រាក[ផ]។ ៥ក្នុងអត្ថ
បទគម្ពីរខាងលើនេះ មានចែងសាជាថ្មីថា៖ «
ពួកគេនឹងមិនបានចូលទៅសម្រាកជាមួយយើង
ជាដាច់ខាត»។

៦ព្រះជាម្ចាស់បានតម្រូវឲ្យអ្នកខ្លះ ចូលទៅ
សម្រាក ក៏ប៉ុន្តែដោយអស់អ្នកដែលទទួល
ដំណឹងល្អពីមុនមិនបានចូល ព្រោះគេមិនស្ដាប់
បង្គាប់ ៧ព្រះអង្គក៏កំណត់យក"ថ្ងៃនេះ"មួយ
ទៀតគឺ ព្រះអង្គមានព្រះបន្ទូលតាមរយៈព្រះ
បាទដាវីឌជាយូរអង្វែង ក្រោយមកទៀតដូច
មានចែងទុកនៅខាងលើនេះស្រាប់ថា៖«ថ្ងៃនេះ
ប្រសិនបើអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះ
អង្គមិនត្រូវមានចិត្តរឹងរូសឡើយ»។

៨ប្រសិនបើលោកយ៉ូស៊ូអានាំប្រជារាស្ត្រឲ្យ
បានសម្រាកមែន ក្រោយមកទៀតនោះព្រះជា
ម្ចាស់មុខជាពុំមានព្រះបន្ទូលអំពីថ្ងៃមួយផ្សេង
ទៀតឡើយ។ ៩ដូច្នេះព្រះជាម្ចាស់បានតម្រូវ
ទុកឲ្យមានថ្ងៃសម្រាកមួយទៀតសម្រាប់ប្រជារា

ស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទី
ប្រាំពីរដែរ ១០ដ្បិតអ្នកណាចូលទៅសម្រាក
ជាមួយព្រះជាម្ចាស់ អ្នកនោះបានបង្ហើយកិច្ច
ការ[៣]របស់ខ្លួន ដូចព្រះជាម្ចាស់បង្ហើយកិច្ចការ
របស់ព្រះអង្គដែរ។ ១១ហេតុនេះយើងត្រូវតែ
ខ្នះខ្នែង ចូលទៅរកសម្រាកជាមួយព្រះអង្គនោះ
វិញ កុំឲ្យមាននរណាម្នាក់ធ្លាក់ខ្លួនទៅយក
តម្រាប់តាម ពួកអ្នកដែលមិនស្ដាប់បង្គាប់នោះ
ឡើយ ១២ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជា
ព្រះបន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិមុត
ជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូលនេះចាក់
ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញ
ពីគ្នា កាត់សន្លាក់ឆ្អឹងនិងខួរឆ្អឹងចេញពីគ្នា។ ព្រះ
បន្ទូលវិនិច្ឆ័យឆន្ទៈនិងគំនិតនៅក្នុងជម្រៅចិត្ត
មនុស្ស។ ១៣គ្មានសត្វលោកណាមួយដែលព្រះ
បន្ទូលមើលមិនឃើញឡើយ ចំពោះព្រះនេត្រ
របស់ព្រះអង្គអ្វីៗទាំងអស់នៅទទេឥតបិទបាំង
ទាល់តែសោះ។ យើងត្រូវទូលរៀបរាប់ថ្វាយ
ព្រះបន្ទូលពីគ្រប់កិច្ចការទាំងអស់។

## ព្រះយេស៊ូជាមហាបូជាចារ្យ ដ៏ខ្ពង់ខ្ពស់លើសមហាបូជាចារ្យ នៃសម្ពន្ធមេត្រីចាស់

១៤ដោយយើងមានមហាបូជាចារ្យ*មួយរូប
ដ៏ប្រសើរឧត្ដម ដែលបានយាងកាត់ស្ថានបរម
សុខ* គឺព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជា
ម្ចាស់ យើងត្រូវតែកាន់ជំនឿដែលយើងប្រកាស
នោះឲ្យបានមាំមួន ១៥ដ្បិតយើងមានមហាបូជា
ចារ្យដែលអាចរួមសុខទុក្ខជាមួយយើងជា
មនុស្សទន់ខ្សោយ គឺព្រះអង្គក៏ត្រូវរងការល្បួង
លគ្រប់ជំពូកដូចយើងដែរ តែទ្រង់មិនបាន
ប្រព្រឹត្តអំពើបាបសោះឡើយ ១៦ហេតុនេះយើង
ត្រូវចូលទៅកាន់បល្ល័ង្ក របស់ព្រះជាម្ចាស់ប្រកប
ដោយព្រះហឫទ័យ ប្រណីសន្ដោស ទាំង
ទុកចិត្ត ដើម្បីឲ្យព្រះអង្គមេត្តាករុណា និងប្រណី
សន្ដោសយើង ព្រមទាំងជួយយើងនៅពេល
ណាយើងត្រូវការ។

១គេជ្រើសរើសមហាបូជាចារ្យគ្រប់ៗរូបពី
៥ចំណោមមនុស្ស ហើយតែងតាំងសម្រាប់ឲ្យ
ទាក់ទងជាមួយព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍
ដល់មនុស្សលោក ក្នុងការថ្វាយតង្វាយ និង
ថ្វាយយញ្ញបូជារំដោះបាបមនុស្ស។ ២លោក
មហាបូជាចារ្យ អាចមានអធ្យាស្រ័យដល់
មនុស្សល្ងីតល្ងង់ និងមនុស្សវង្វេងបាន ព្រោះ
ខ្លួនលោកផ្ទាល់ក៏ទន់ខ្សោយ ៣ហើយដោយ
លោកទន់ខ្សោយដូច្នេះ លោកត្រូវថ្វាយយញ្ញ
បូជាសម្រាប់ឲ្យខ្លួនលោកផ្ទាល់ និងប្រជារាស្ត្រ
រួចពីបាប។ ៤គ្មាននរណាតាំងខ្លួនឯង ឲ្យ
បំពេញមុខងារដ៏ប្រសើរនេះបានឡើយ គឺទាល់
តែព្រះជាម្ចាស់ត្រាស់ហៅដូចលោកអរ៉ូន ទើប
បំពេញបាន។
៥រីឯព្រះគ្រិស្តវិញក៏ដូច្នោះដែរ ព្រះអង្គពុំ
បានលើកតម្កើងព្រះអង្គផ្ទាល់ ធ្វើជាមហាបូជា
ចារ្យឡើយ គឺព្រះជាម្ចាស់ទេតើដែលបាន
តែងតាំងព្រះអង្គដោយមានព្រះបន្ទូលមកកាន់
ព្រះអង្គថា៖

*«ព្រះអង្គជាបុត្ររបស់យើង*
*គឺយើងហ្នឹងហើយដែលបានទទួលព្រះអង្គ*
*ធ្វើជាបុត្រនៅថ្ងៃនេះ»*[ភ]។

៦ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលនៅក្នុងវគ្គ
មួយទៀតថា៖

*«ព្រះអង្គជាបូជាចារ្យអស់កល្បតរៀងទៅ*
*តាមរបៀបព្រះបាទមែលគីសេដែក»*[ម]។

៧កាលព្រះគ្រីស្ដរស់នៅក្នុងលោកនេះនៅ
ឡើយ ព្រះអង្គបានបន្លឺសំឡេងយ៉ាងខ្លាំង និង
បង្ហូរទឹកភ្នែកទូលអង្វរ ទូលសូមព្រះជាម្ចាស់
ដែលអាចសង្គ្រោះព្រះអង្គ ឲ្យរួចពីស្លាប់។
ដោយព្រះគ្រីស្ដ បានគោរពប្រណិប័តន៍ព្រះជា
ម្ចាស់នោះព្រះជាម្ចាស់ ក៏ប្រោសប្រទានតាម
ពាក្យទូលអង្វរ។ ៨ថ្វីដ្បិតតែ ព្រះអង្គជាព្រះ
បុត្រាក៏ដោយ ព្រះអង្គក៏បានរៀនស្ដាប់បង្គាប់
ដោយរងទុក្ខលំបាក។ ៩បន្ទាប់ពីព្រះអង្គបាន
គ្រប់លក្ខណៈហើយ ទ្រង់ក៏បានទៅជាប្រភពនៃ
ការសង្គ្រោះដ៏នៅស្ថិតស្ថេរ អស់កល្បជានិច្ច
សម្រាប់អស់អ្នក ដែលស្ដាប់បង្គាប់ព្រះអង្គ
១០ហើយព្រះជាម្ចាស់ក៏ប្រកាស តែងតាំងព្រះ
អង្គជាមហាបូជាចារ្យ តាមរបៀបព្រះបាទមែល
គីសេដែកដែរ។

## ពាក្យដាស់តឿនឲ្យគេស៊ូ ស្មោះត្រង់នឹងជំនឿ

១១ត្រង់ចំណុចនេះ យើងមានសេចក្ដីជា
ច្រើនដែលត្រូវនិយាយជាសេចក្ដីដែលពិបាក
ពន្យល់ ព្រោះបងប្អូនបែរជាក្រនឹងយល់។
១២ តាមពិតបងប្អូនគួរតែបានធ្វើជាគ្រូបង្រៀន
គេតាំងពីយូរយារណាស់មកហើយ ក៏ប៉ុន្តែបង
ប្អូនត្រូវការឲ្យគេបង្រៀនអំពីសេចក្ដីខ្លះៗ ដែល
នៅខាងដើមដំបូង នៃព្រះបន្ទូលរបស់ព្រះជា
ម្ចាស់ឡើងវិញបងប្អូនបែរជាត្រូវការទឹកដោះ គឺ
មិនមែនត្រូវការអាហាររឹងទេ។ ១៣អ្នកដែលត្រូវ
ការទឹកដោះពុំអាចយល់ការប្រៀនប្រដៅ អំពី
សេចក្ដីសុចរិត[យ]បានឡើយ ព្រោះគេនៅជាកូន
ខ្ចី។ ១៤មានតែមនុស្សពេញវ័យ[រ]ប៉ុណ្ណោះដែល
អាចទទួលអាហាររឹងបាន ព្រោះគេធ្លាប់មានការ
ពិសោធន៍ ចេះវែកញែក ស្គាល់ល្អស្គាល់អាក្រ
ក់។

១ហេតុនេះ ត្រូវឈោងចាប់យកសេចក្ដីណា
៦ដែលមានខ្លឹមសារគ្រប់លក្ខណៈរបស់មនុស្ស
ពេញវ័យ ដោយទុកសេចក្ដីផ្សេងៗនៅដើម
ដំបូង ស្ដីអំពីព្រះគ្រីស្ដនោះសិន យើងមិនបាច់
ចាក់គ្រឹះសាជាថ្មីទៀតទេ គឺដូចជានិយាយអំពី
ការកែប្រែចិត្តគំនិត ឈប់ប្រព្រឹត្តអំពើឥតបាន
ការ[ល] អំពីជំនឿលើព្រះជាម្ចាស់ ២អំពីសេចក្ដី
បង្រៀនពីការជ្រមុជផ្សេងៗ អំពីពិធីដាក់ដៃ*
អំពីការរស់ឡើងវិញ ឬអំពីការវិនិច្ឆ័យទោស
អស់កល្បជានិច្ចនោះឡើយ។ ៣ប្រសិនបើព្រះ
ជាម្ចាស់សព្វព្រះហឫទ័យយើងនឹងបរិយាយអំពី
សេចក្ដីដូចតទៅនេះ។

៤មានអ្នកខ្លះបានទទួលពន្លឺម្ដងរួចហើយ
ថែមទាំងបានស្គាល់ឱជារស នៃព្រះអំណោយ
ទានពីស្ថានបរមសុខ* បានរួមចំណែកជាមួយ
ព្រះវិញ្ញាណដ៏វិសុទ្ធ* ៥ព្រមទាំងស្គាល់ឱជារស

នៃព្រះបន្ទូលដ៏ល្អវិសេសរបស់ព្រះជាម្ចាស់ និង
ស្គាល់ឫទ្ធានុភាពទាំងឡាយ នៃបរលោកទៀត
ផង។ ៦ប្រសិនបើគេបែរជាធ្លាក់ខ្លួនបាត់ជំនឿ
វិញ នោះគេមុខជាពុំអាចកែប្រែចិត្តគំនិតសាជា
ថ្មីម្ដងទៀតបានឡើយ ដ្បិតខ្លួនគេផ្ទាល់បាន
ឆ្កាងព្រះបុត្រារបស់ព្រះជាម្ចាស់ សាជាថ្មី ព្រម
ទាំងបានបន្ថោកកិត្តិយសព្រះអង្គ ជាសាធារ
ណៈផង។

៧ដីណាទទួលទឹកភ្លៀង ដែលធ្លាក់មកជា
ញឹកញាប់ ហើយផ្ដល់ភោគផលល្អដល់អ្នកភ្ជួរ
រាស់ ដីនោះក៏ទទួលព្រះពរពីព្រះជាម្ចាស់ដែរ។
៨ផ្ទុយទៅវិញ ប្រសិនបើដីនោះដុះសុទ្ធតែបន្លា
និងអញ្ចាញគេនឹងចាត់ទុកថា គ្មានតម្លៃជិតត្រូវ
បណ្ដាសា ហើយគេមុខជាដុតចោលមិនខាន។

៩ក៏ប៉ុន្តែបងប្អូនដ៏ជាទីស្រឡាញ់អើយ ទោះ
បីយើងនិយាយបែបនេះក៏ដោយ ក៏យើងជឿ
ជាក់ថា បងប្អូនស្ថិតនៅលើមាគ៌ាដ៏ល្អប្រសើរ
បំផុត ឆ្ពោះទៅរកការសង្គ្រោះ ១០ដ្បិតព្រះជា
ម្ចាស់មិនមែនអយុត្តិធម៌ទេ ទ្រង់មិនភ្លេចអំពើ
ដែលបងប្អូនបានប្រព្រឹត្ត ហើយក៏មិនភ្លេច
សេចក្ដីស្រឡាញ់ ដែលបងប្អូនបានសម្ដែង
ចំពោះព្រះនាមព្រះអង្គ ដោយបងប្អូនបានបម្រើ
ប្រជាជនដ៏វិសុទ្ធកាលពីដើមនិងឥឡូវនេះដែរ។
១១យើងចង់ឲ្យបងប្អូនម្នាក់ៗ នៅតែមានចិត្តខ្នះ
ខ្នែងរហូតដល់ចុងបញ្ចប់ គឺធ្វើឲ្យសេចក្ដីសង្ឃឹម
របស់បងប្អូនបានពេញលក្ខណៈ ១២ដើម្បីកុំឲ្យ
បងប្អូនក្លាយទៅជាខ្ជិលច្រអូស តែឲ្យយក
តម្រាប់តាមអស់អ្នក ដែលបានទទួលមត៌កតាម
ព្រះបន្ទូលសន្យា ព្រោះគេមានជំនឿនិងចេះស៊ូ
ទ្រាំ។

## ព្រះបន្ទូលសន្យា ដែលមិនចេះប្រែប្រួល

១៣នៅពេល ដែលព្រះជាម្ចាស់មានព្រះ
បន្ទូលសន្យានឹងលោកអប្រាហាំ ព្រះអង្គបាន
ស្បថ ដោយយកព្រះអង្គផ្ទាល់ធ្វើជាប្រធាន
ព្រោះគ្មាននរណាមានឋានៈធំជាងព្រះអង្គធ្វើជា
ប្រធានសម្បថបានឡើយ។ ១៤ព្រះអង្គមានព្រះ
បន្ទូលថា៖ «យើងនឹងឲ្យពរអ្នកយ៉ាងច្រើនបរិបូ
ណ៌ ហើយក៏នឹងធ្វើឲ្យពូជពង្សរបស់អ្នកបាន
កើនចំនួនច្រើនឡើងដែរ»[រ]។ ១៥ដោយលោកអ
ប្រាហាំព្យាយាមទន្ទឹងរង់ចាំលោក ក៏បានទទួល
តាមព្រះបន្ទូលសន្យាមែន។ ១៦មនុស្សតែងតែ
ស្បថ ដោយយកអ្វីៗធំជាងខ្លួន មកធ្វើជា
ប្រធាន ហើយសម្បថនោះធ្វើឲ្យពាក្យសំដីរបស់
គេយកជាការបាន ដើម្បីបញ្ចប់ការទាស់ទែងគ្នា
គ្រប់យ៉ាង។ ១៧ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យ
បង្ហាញឲ្យអស់អ្នកដែលទទួលមត៌កតាមព្រះ
បន្ទូលសន្យា បានដឹងរឹតតែច្បាស់ថា បើព្រះអង្គ
សម្រេចព្រះហឫទ័យយ៉ាងណាហើយនោះ
ទ្រង់មិនប្រែប្រួលទេ។ ហេតុនេះព្រះអង្គមាន
ព្រះបន្ទូលស្បថ ថែមលើព្រះបន្ទូលសន្យាទៀ
ត។ ១៨ចំពោះយើងដែលបានលះបង់អ្វីៗទាំង
អស់ ដើម្បីឈោងចាប់យកសេចក្ដីសង្ឃឹម
ដែលព្រះអង្គដាក់នៅខាងមុខយើងព្រះអង្គក៏

បានលើកទឹកចិត្តយើង យ៉ាងខ្លាំងដោយមាន
ព្រះបន្ទូលទាំងពីរយ៉ាង[ស] ដែលពុំចេះប្រែប្រួល
ហើយព្រះជាម្ចាស់មិនចេះកុហកក្នុងព្រះបន្ទូល
នេះឡើយ។ ១៩សេចក្តីសង្ឃឹមនេះ ប្រៀបបីដូច
ជាយុថ្កាមួយដ៏ជាប់មាំមួនសម្រាប់ព្រលឹងរបស់
យើង ហើយក៏បានចូលហួសវាំងនន ទៅក្នុងទី
សក្ការៈថែមទៀតផង ២០គឺឆ្ពោះទៅកាន់កន្លែង
ដែលព្រះយេស៊ូបានយាងចូលទៅមុន ដើម្បីជា
ប្រយោជន៍ដល់យើង ហើយព្រះអង្គក៏បាន
ទទួលឋានៈជាមហាបូជាចារ្យ*រហូតអស់កល្ប
ជានិច្ច តាមរបៀបព្រះបាទមែលគីសេដែក។

## ព្រះបាទមែលគីសេដែក ជាមហាក្សត្រ និងជាបូជាចារ្យ

១ព្រះបាទមែលគីសេដែកនេះ ជាព្រះមហា
ក្សត្រនៅក្រុងសាឡឹម និងជាបូជាចារ្យ*របស់
ព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ទ្រង់បានទៅជួបលោកអ
ប្រាហាំ ដែលវិលមកពីវាយឈ្នះស្តេចនានា
ហើយទ្រង់ជូនពរលោក[ហ]។ ២លោកអប្រាហាំ
បានយកអ្វីៗទាំងអស់ដែលលោកមានចំនួន
មួយភាគដប់ មកថ្វាយព្រះបាទមែលគីសេដែ
ក។ ព្រះនាមរបស់ស្តេចអង្គនេះមានន័យថា«
ស្តេចប្រកបដោយសេចក្តីសុចរិត»ហើយទ្រង់
ជាស្តេចក្រុងសាឡឹមថែមទៀត ដែលមានន័យ
ថា«ស្តេចនៃសេចក្តីសុខសាន្ត»។ ៣ទ្រង់គ្មាន
មាតាបិតា និងគ្មានវង្សត្រកូលទេ ហើយជីវិត
របស់ស្តេចក៏គ្មានដើមកំណើត និងចុងបញ្ចប់ដែ
រ។ ទ្រង់ដូចព្រះបុត្រារបស់ព្រះជាម្ចាស់ហើយ
ស្ថិតនៅជាបូជាចារ្យ*រហូតតរៀងទៅ។

៤សូមបងប្អូនពិចារណាមើលចុះ ព្រះបាទ
មែលគីសេដែកនេះមានឋានៈធំប៉ុនណា បាន
ជាលោកអប្រាហាំបុព្វបុរស*របស់យើង យក
អ្វីៗដែលលោករឹបអូសបានពីចម្បាំង ចំនួនមួយ
ភាគដប់មកថ្វាយដូច្នេះ! ៥អស់អ្នកក្នុងពូជពង្ស
របស់លោកលេវី* ដែលបានទទួលមុខងារជា
បូជាចារ្យ*មានសិទ្ធិនឹងទារយកតង្វាយ មួយ
ភាគដប់*ពីប្រជាជន ស្របតាមវិន័យ*គឺទារ
យកពីអស់អ្នកជាសាច់ឈាមរបស់ខ្លួន ដែលជា
ពូជពង្សរបស់លោកអប្រាហាំដូចគ្នា។៦ចំណែក
ឯព្រះបាទមែលគីសេដែកវិញ លោកគ្មានជាប់
សាច់ញាតិអ្វីនឹងកូនចៅលោកលេវីទេ តែលោក
បានយកទ្រព្យ ចំនួនមួយភាគដប់ ពីលោកអ
ប្រាហាំ! ទ្រង់ក៏ជូនពរដល់លោកអប្រាហាំដែល
បានទទួលព្រះបន្ទូលសន្យា! ៧ធម្មតាអ្នកទទួល
ពរមានឋានៈតូចជាងអ្នកឲ្យពរ ត្រង់ចំណុចនេះ
យើងពុំអាចប្រកែកបានឡើយ។ ៨លោកលេវី
ឡ ដែលទទួលតង្វាយមួយភាគនោះជាមនុស្ស
រមែងតែងតែស្លាប់។ រីឯព្រះបាទមែលគីសេ
ដែកវិញ ទ្រង់មានព្រះជន្មរស់ដូចគម្ពីរបាន
បញ្ជាក់ស្រាប់។ ៩យើងអាចពោលឲ្យអស់
សេចក្តីថា សូម្បីតែលោកលេវី[ឡ]ដែលតែង
ទទួលតង្វាយមួយភាគដប់ ក៏បានយកអ្វីៗមួយ
ភាគដប់ថ្វាយព្រះបាទមែលគីសេដែក តាមរ
យៈលោកអប្រាហាំដែរ ១០ដ្បិតនៅពេលដែល
ព្រះបាទមែលគីសេដែកទៅជួបលោកអប្រាហាំ
នោះ លោកលេវីស្ថិតនៅក្នុងលោកអប្រាហាំនៅ

ឡើយ។

១១មុខងារបូជាចារ្យ ជាគ្រឹះនៃធម្មវិន័យរបស់
ប្រជារាស្ត្រអ៊ីស្រាអែល។ ប្រសិនបើមុខងារជា
បូជាចារ្យបានគ្រប់លក្ខណៈដោយសារពួកលេវី
ហើយនោះ តើចាំបាច់តែងតាំងបូជាចារ្យមួយ
ទៀត តាមរបៀបព្រះបាទមែលគីសេដែកធ្វើអ្វី?
ម្ដេចក៏មិននិយាយពីបូជាចារ្យតាមរបៀបលោក
អរ៉ុនទៅវិញ។ ១២ប្រសិនបើមានការផ្លាស់ប្ដូរមុខ
ងារបូជាចារ្យនោះ ក៏ត្រូវតែមានការផ្លាស់ប្ដូរវិ
ន័យដែរ។ ១៣រីឯបូជាចារ្យដែលមានចែងក្នុង
អត្ថបទទាំងនេះទ្រង់កើតក្នុងកុលសម្ព័ន្ធមួយ
ដែលគ្មាននរណាម្នាក់ធ្លាប់ធ្វើជាបូជាចារ្យឡើយ
[អ]។ ១៤យើងសុទ្ធតែបានដឹងច្បាស់ទាំងអស់គ្នា
ថា ព្រះអម្ចាស់នៃយើងប្រសូតមកក្នុង
កុលសម្ព័ន្ធ*យូដា។ ពេលលោកម៉ូសេនិយាយ
អំពីបូជាចារ្យ លោកពុំដែលនិយាយពីកុលស
ម្ព័ន្ធនេះទេ។ ១៥ប្រសិនបើមានការតែងតាំង
បូជាចារ្យមួយរូបទៀត ដូចព្រះបាទមែលគីសេ
ដែក សេចក្ដីនេះក៏រឹតតែច្បាស់ជាងទៅទៀត។
១៦ព្រះអង្គ[ក]មិនបានទទួលមុខងារជាបូជាចារ្យ
តាមវិន័យក្រឹត្យក្រមរបស់មនុស្សលោកឡើយ
គឺទ្រង់បានទទួលមុខងារនេះតាមឫទ្ធានុភាពនៃ
ព្រះជន្មមិនចេះសាបសូន្យ ១៧ដ្បិតគម្ពីរបាន
ផ្ដល់សក្ខីភាពអំពីព្រះអង្គថា«ព្រះអង្គជាបូជាចា
រ្យអស់កល្បតរៀងទៅ តាមរបៀបព្រះបាទមែល
គីសេដែក»[ខ]។ ១៨ដូច្នេះបញ្ញត្តិដែលមានពីមុន
មក ត្រូវលុបបំបាត់ចោលហើយព្រោះគ្មាន
ប្រសិទ្ធភាពគ្មានសារប្រយោជន៍អ្វីទេ ១៩ដ្បិតវិ
ន័យពុំបានធ្វើឲ្យអ្វីមួយ ទៅជាគ្រប់លក្ខណៈឡើ
យ។ ម៉្យាងទៀតសេចក្ដីសង្ឃឹមមួយដ៏ប្រសើរ
ជាង បានមកដល់ហើយ ដោយសារសេចក្ដី
សង្ឃឹមនេះ យើងអាចចូលទៅជិតព្រះជាម្ចាស់
បាន។

២០លើសពីនេះ មានព្រះបន្ទូលសម្បថ។
បូជាចារ្យឯទៀតៗ បានទទួលមុខងារ ជាបូជា
ចារ្យ ដោយគ្មានព្រះបន្ទូលសម្បថទេ។ ២១រីឯ
ព្រះយេស៊ូវិញ ទ្រង់បានទទួលមុខងារជាបូជាចា
រ្យដោយព្រះជាម្ចាស់ទ្រង់បានស្បថ គឺព្រះជា
ម្ចាស់មានព្រះបន្ទូលមកកាន់ព្រះអង្គថា«*"ព្រះ
អង្គជាបូជាចារ្យអស់កល្បជានិច្ច" ព្រះអម្ចាស់
ទ្រង់បានស្បថ ហើយទ្រង់នឹងមិនប្រែប្រួល
ឡើយ*»[គ]។ ២២ដូច្នេះដោយមានព្រះបន្ទូល
សម្បថយ៉ាងនេះបានសេចក្ដីថាព្រះយេស៊ូធានា
រ៉ាប់រងនូវសម្ព័ន្ធមេត្រី*មួយរឹតតែប្រសើរជាង
ទៅទៀត។

២៣លើសពីនេះ មានគ្នាជាច្រើនបានធ្វើបូជា
ចារ្យតៗគ្នា ព្រោះពួកគេតែងតែស្លាប់ពុំអាចធ្វើ
បូជាចារ្យជាអចិន្ត្រៃយ៍បានឡើយ។ ២៤រីឯព្រះ
យេស៊ូវិញព្រះអង្គមានមុខងារជាបូជាចារ្យដែល
ពុំអាចផ្ទេរទៅឲ្យនរណាបានទេ ព្រោះព្រះអង្គ
គង់នៅអស់កល្បជានិច្ច។ ២៥ហេតុនេះហើយ
បានជា ព្រះអង្គក៏អាចសង្គ្រោះអស់អ្នកដែល
ចូលមកជិតព្រះជាម្ចាស់ តាមរយៈព្រះអង្គបាន
ជាស្ថាពរ ដ្បិតព្រះអង្គមានព្រះជន្មរស់រហូត
ដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យពួកគេ។ ២៦មាន

តែមហាបូជាចារ្យដ៏ប្រសើរ ដូចព្រះយេស៊ូនេះ
ហើយ ដែលយើងត្រូវការ គឺមហាបូជាចារ្យដ៏
វិសុទ្ធ ស្លូតត្រង់ ឥតសៅហ្មង ខុសប្លែកពី
មនុស្សបាប ព្រមទាំងខ្ពង់ខ្ពស់លើសស្ថានបរម
សុខ*ទៅទៀត។ ២៧ព្រះអង្គមិនត្រូវការថ្វាយ
យញ្ញបូជារៀងរាល់ថ្ងៃ ដូចមហាបូជាចារ្យ
ឯទៀតៗថ្វាយ ព្រោះបាបខ្លួនឯងផ្ទាល់ផង និង
បាបប្រជាជនផងនោះឡើយ ដ្បិតព្រះអង្គបាន
ថ្វាយព្រះកាយព្រះអង្គផ្ទាល់ជាយញ្ញបូជាម្ដងជា
សូរេច។ ២៨វិន័យបានតែងតាំងមនុស្សទន់
ខ្សោយឲ្យធ្វើជាមហាបូជាចារ្យ។ រីឯព្រះបន្ទូល
សម្បថដែលមានមកតាមក្រោយវិន័យ បាន
តែងតាំងព្រះបុត្រាដែលគ្រប់លក្ខណៈអស់
កល្បជានិច្ច ឲ្យធ្វើជាមហាបូជាចារ្យវិញ។

## ព្រះយេស៊ូជាមហាបូជាចារ្យ នៃសម្ពន្ធមេត្រីថ្មី

១គោលដ៏សំខាន់បំផុត ក្នុងសេចក្ដីដែលយើង
៨កំពុងតែបរិយាយនេះ គឺថាយើងមានមហា
បូជាចារ្យ*មួយ គង់នៅខាងស្ដាំបល្ល័ង្ករបស់ព្រះ
ជាម្ចាស់ដ៏ឧត្ដុង្គឧត្ដម នៅស្ថានបរមសុខ។ ២
ព្រះអង្គនៅបម្រើក្នុងទីសក្ការៈ* និងក្នុងព្រះ
ពន្លា*ដ៏ពិតប្រាកដដែលព្រះអម្ចាស់បានដំឡើង
គឺមិនមែនមនុស្សដំឡើងទេ។ ៣ចំពោះមហា
បូជាចារ្យគ្រប់ៗរូប គេតែងតាំងឲ្យថ្វាយតង្វាយ
និងថ្វាយយញ្ញបូជា ដូច្នេះលោកត្រូវតែរកអ្វី
យកទៅថ្វាយ ជាចាំបាច់។ ៤ប្រសិនបើ ព្រះគ្រី
ស្ដគង់នៅផែនដីនេះព្រះអង្គមិនមែនជាបូជាចា
រ្យទេ ព្រោះមានបូជាចារ្យឯទៀតៗ សម្រាប់យក
តង្វាយទៅថ្វាយ ស្របតាមវិន័យរួចស្រេចទៅ
ហើយ។ ៥អ្នកទាំងនោះធ្វើពិធីផ្សេងៗតាមគំរូ
និងតាមស្រមោលនៃពិធីនៅស្ថានបរមសុខ ដូច
ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ
នៅពេលដែលហៀបនឹងសង់ព្រះពន្លាថា៖ «ចូរ
ប្រុងប្រយ័ត្ន អ្នកត្រូវធ្វើសព្វគ្រប់ទាំងអស់ តាម
គំរូដែលយើងបានបង្ហាញឲ្យអ្នកឃើញនៅលើ
ភ្នំ»[យ]។ ៦ឥឡូវនេះព្រះគ្រីស្ដបានទទួលមុខងារ
ប្រសើរជាងបូជាចារ្យទាំងនោះទៅទៀត ព្រោះ
ព្រះអង្គជាស្ពាន នៃសម្ពន្ធមេត្រី*មួយប្រសើរ
ជាងជាសម្ពន្ធមេត្រី ដែលចងឡើងដោយសារ
ព្រះបន្ទូលសន្យាដ៏ប្រសើរជាង។
៧ប្រសិនបើ សម្ពន្ធមេត្រីមុនល្អឥតខ្ចោះ
ហើយ មិនបាច់រកសម្ពន្ធមេត្រីទីពីរមកជំនួស
ឡើយ។ ៨ព្រះជាម្ចាស់មានព្រះបន្ទូល ស្ដី
បន្ទោសប្រជារាស្ត្ររបស់ព្រះអង្គដូចតទៅ៖

ព្រះអម្ចាស់មានព្រះបន្ទូលថា៖
*«បន្ដិចទៀតយើងនឹងចងសម្ពន្ធមេត្រីមួយថ្មី*
*ជាមួយពូជពង្សរបស់អ៊ីស្រាអែល*
*និងពូជពង្សរបស់យូដា។*
៩ *សម្ពន្ធមេត្រីថ្មីនេះមិនដូចសម្ពន្ធមេត្រីដែល*
*យើងបានចងជាមួយបុព្វបុរសរបស់គេ*
*នៅថ្ងៃដែលយើងដឹកដៃបុព្វបុរសទាំងនោះ*
*ចេញពីស្រុកអេស៊ីបឡើយ។*
*ពួកគេពុំបានគោរពតាមសម្ពន្ធមេត្រី*
*ដែលយើងបានចងជាមួយគេនោះ*
*ឲ្យបានខ្ជាប់ខ្ជួនទេ*

*យើងក៏លែងរវីរវល់នឹងពួកគេដែរ»*
*នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។*
១០ព្រះអម្ចាស់មានព្រះបន្ទូលថា៖
*«លុះគ្រានេះកន្លងផុតទៅ*
*យើងនឹងចងសម្ពន្ធមេត្រីជាមួយពូជពង្ស*
*អ៊ីស្រាអែលដូចតទៅ៖*
*យើងនឹងដាក់វិន័យរបស់យើង*
*ក្នុងប្រាជ្ញារបស់ពួកគេ*
*យើងនឹងចារវិន័យទាំងនោះទុក*
*នៅក្នុងចិត្តរបស់ពួកគេ*
*យើងនឹងបានទៅជាព្រះរបស់ពួកគេ*
*ហើយគេជាប្រជារាស្ដ្ររបស់យើង។*
១១ *ពេលនោះនឹងលែងមាននរណា*
*បង្រៀនជនរួមជាតិរបស់ខ្លួន*
*ហើយក៏លែងមាននរណានិយាយប្រាប់*
*បងប្អូនរបស់ខ្លួនថា*
*"ត្រូវតែស្គាល់ព្រះអម្ចាស់" ទៀតហើយ*
*ព្រោះតាំងពីអ្នកតូចបំផុតរហូតដល់អ្នកធំ*
*គេនឹងស្គាល់យើងគ្រប់ៗគ្នា*
១២ *ដ្បិតយើងនឹងអត់ឱនឲ្យគេ*
*ចំពោះអំពើទុច្ចរិតដែលគេបានប្រព្រឹត្ត*
*ហើយយើងក៏មិននឹកនាពីអំពើបាបរបស់គេ*
*ទៀតដែរ»*[ង]។
១៣ដោយព្រះអង្គហៅសម្ពន្ធមេត្រីនេះថា ជា
សម្ពន្ធមេត្រីថ្មីដូច្នេះ ព្រះអង្គចាត់ទុកសម្ពន្ធ
មេត្រីមុនថា ជាសម្ពន្ធមេត្រីចាស់។ ធម្មតាអ្វីៗ
ដែលចាស់ ហើយកាន់តែចាស់ទៅៗនោះមុខជា
ត្រូវសាបសូន្យ បាត់ទៅមិនខាន។

## ការគោរពថ្វាយបង្គំព្រះជាម្ចាស់ តាមរបៀបចាស់ និង តាមរបៀបថ្មី

១ក្នុងសម្ពន្ធមេត្រីទីមួយ មានក្បួនផ្សេងៗ
៩សម្រាប់គោរពបម្រើព្រះជាម្ចាស់ និងមានទី
សក្ការៈនៅលើផែនដីនេះ ២ព្រោះគេបាន
ដំឡើងព្រះពន្លា*មួយ ហើយគេហៅផ្នែកខាង
មុខថា "ទីសក្ការៈ" នៅទីនោះមានដាក់ជើង
ចង្កៀង តុ និង នំប៉័ងតង្វាយ។ ៣បន្ទាប់មកខាង
ក្រោយវាំងននទីពីរ មានព្រះពន្លាមួយទៀតហៅ
ថា"ទីសក្ការៈបំផុត"។ ៤នៅទីនោះមានភាជន៍
មួយធ្វើពីមាស សម្រាប់ដុតគ្រឿងក្រអូប និង
មានហិប*នៃសម្ពន្ធមេត្រី ស្រោបមាសជុំវិញ
ហើយក្នុងហិបនោះ មានពានមាសមួយដែលគេ
ដាក់នំម៉ាណា មានដំបងរបស់លោកអរ៉ុនដែល
មានផ្ការីកចេញមក និងមានបន្ទះថ្មនៃសម្ពន្ធ
មេត្រីផង។ ៥នៅពីលើហិបនៃសម្ពន្ធមេត្រីមាន
រូបខេរូប៊ីម* ត្រដាងស្លាបបាំងពីលើកន្លែងថ្វាយ
ឈាមសុំឲ្យរួចពីបាប* រូបនោះបង្ហាញពីវត្តមាន
របស់ព្រះជាម្ចាស់[ច]។ ប៉ុន្តែយើងមិនបាច់រៀប
រាប់ឲ្យបានល្អិតល្អន់ នៅពេលនេះទេ។ ៦អ្វីៗ
ទាំងអស់រៀបរយដូច្នេះហើយ ក្រុមបូជាចារ្យក៏
នាំគ្នាចូលទៅគោរពបម្រើ នៅផ្នែកខាងមុខនៃ
ព្រះពន្លានោះជាប្រក្រតី។ ៧រីឯព្រះពន្លាខាងក្នុង
វិញ មានតែលោកមហាបូជាចារ្យប៉ុណ្ណោះដែល
ចូលទៅបានមួយឆ្នាំម្ដង។ លោកត្រូវតែយក
ឈាមសត្វចូលទៅថ្វាយព្រះជាម្ចាស់ ដើម្បី
លាងកំហុសរបស់ខ្លួនលោកផ្ទាល់ និងកំហុស
របស់ប្រជាជន។ ៨ត្រង់នេះព្រះវិញ្ញាណដ៏

វិសុទ្ធ*បង្ហាញឲ្យយើងដឹងថា ដរាបណាផ្នែក
ខាងមុខនៃព្រះពន្លានៅស្ថិតស្ថេរនៅឡើយ ផ្លូវ
ចូលទៅក្នុងទីសក្ការៈ ក៏ពុំទាន់បើកចំហឲ្យយើង
ចូលទៅបានដែរ។ ៩នេះហើយជានិមិត្តរូប
សម្រាប់បច្ចុប្បន្នកាល គឺមានន័យថា តង្វាយ
និងយញ្ញបូជាដែលមនុស្សយកមកថ្វាយព្រះជា
ម្ចាស់ ពុំអាចធ្វើឲ្យមនសិការរបស់អ្នកដែលមក
គោរពបម្រើ ទៅជាគ្រប់លក្ខណៈបានឡើយ។
១០ពិធីទាំងនោះ គ្រាន់តែជាក្បួនតម្រាខាង
លោកីយ៍អំពីម្ហូបអាហារភេសជ្ជៈ និងអំពីការ
ប្រោះទឹកផ្សេងៗប៉ុណ្ណោះជាពិធីដែលប្រជាជន
ត្រូវធ្វើទម្រាំដល់ពេលព្រះជាម្ចាស់កែទម្រង់អ្វីៗ
ទាំងអស់ឡើងវិញ។

១១រីឯព្រះគ្រីស្ដវិញ ព្រះអង្គបានយាងមក
ក្នុងឋានៈជាមហាបូជាចារ្យ ដែលនាំទៅកាន់ស
ម្បត្តិនៅលោកខាងមុខ។ ព្រះអង្គបានយាង
កាត់ព្រះពន្លាមួយដ៏ប្រសើរឧត្ដម និងល្អគ្រប់
លក្ខណៈជាង ជាព្រះពន្លាដែលមិនមែនសង់
ឡើងដោយដៃមនុស្ស ពោលគឺមិនមែនជាព្រះ
ពន្លាដែលស្ថិតនៅក្នុងលោកនេះឡើយ។១២ព្រះ
អង្គពុំបានយកឈាមពពែឈ្មោល ឬឈាមកូន
គោទេ គឺយកព្រះលោហិតរបស់ព្រះអង្គផ្ទាល់
ចូលទៅថ្វាយក្នុងទីសក្ការៈម្ដង ជាសូរេចទាំង
លោះយើងអស់កល្បជានិច្ចផង។ ១៣ប្រសិនបើ
ឈាមពពែឈ្មោល និងឈាមគោបា ព្រមទាំង
ផេះ គោញី ស្ទាវ ដែលគេបាចលើមនុស្ស
សៅហ្មងធ្វើឲ្យរូបកាយគេបានបរិសុទ្ធ និងឲ្យគេ
ទៅជាវិសុទ្ធយ៉ាងហ្នឹងទៅហើយ ១៤ចំណង់បើ
ព្រះលោហិតរបស់ព្រះគ្រីស្ដវិញ តើនឹងរឹតតែ
ជម្រះមនសិការយើងឲ្យបានរួចផុតពីអំពើឥត
បានការ ដើម្បីគោរពបម្រើព្រះជាម្ចាស់ដ៏មាន
ព្រះជន្មរស់ខ្លាំងយ៉ាងណាទៅទៀត? គឺដោយ
សារព្រះវិញ្ញាណ ដែលគង់នៅអស់កល្បជានិច្ច
ព្រះគ្រីស្ដបានថ្វាយព្រះអង្គផ្ទាល់ ទៅព្រះជា
ម្ចាស់ ទុកដូចជាយញ្ញបូជាឥតសៅហ្មង។

១៥ហេតុនេះព្រះអង្គជាស្ពាននៃសម្ព័ន្ធមេត្រី
មួយថ្មី ដើម្បីឲ្យអស់អ្នកដែលព្រះជាម្ចាស់ត្រាស់
ហៅទទួលមត៌កដ៏ស្ថិតស្ថេរ អស់កល្បជានិច្ច
តាមព្រះបន្ទូលសន្យា ព្រោះព្រះគ្រីស្ដបាន
សោយទិវង្គតដើម្បីលោះមនុស្សលោក ឲ្យរួច
ផុតពីទោសដែលគេបានប្រព្រឹត្តល្មើស កាល
នៅក្រោមសម្ព័ន្ធមេត្រីទីមួយ។

១៦ធម្មតា គេអាចចែកកេរមត៌កតាមពាក្យ
បណ្ដាំបាន លុះត្រាតែមានសេចក្ដីបញ្ជាក់ថា
អ្នកដែលបានចែងពាក្យបណ្ដាំនោះ ស្លាប់ទៅ
ហើយ ១៧ព្រោះពាក្យបណ្ដាំអាចយកជាការ
បាន តែនៅពេលណាដែលម្ចាស់បណ្ដាំនោះ
ស្លាប់ប៉ុណ្ណោះ បើម្ចាស់បណ្ដាំនៅរស់គេពុំអាច
អនុវត្តតាមពាក្យបណ្ដាំនោះបានឡើយ។ ១៨
ហេតុនេះសូម្បីតែសម្ព័ន្ធមេត្រីពីមុនក៏ចាប់ផ្ដើម
យកជាការបានទាល់តែមានការបង្ហូរឈាម។
១៩ពេលលោកម៉ូសេប្រកាសបញ្ញត្តិទាំងអស់
ស្របតាមវិន័យ* ឲ្យប្រជាជនទាំងមូលស្ដាប់រួច
ហើយលោកយករោមចៀមដែលជ្រលក់ពណ៌
ក្រហមនិងស្លឹកហ៊ីសុប[ឆ] មកជ្រលក់ឈាមកូន

គោ ឈាមពពែឈ្មោលនិងទឹក ប្រោះលើគម្ពីរ
ព្រមទាំងលើប្រជាជនទាំងមូល ២០លោកមាន
ប្រសាសន៍ថា៖ «នេះជាលោហិតនៃសម្ព័ន្ធ
មេត្រីដែលព្រះជាម្ចាស់បានបង្គាប់ឲ្យអ្នករាល់
គ្នាកាន់តាម»[ជ]។ ២១បន្ទាប់មកលោកក៏បាន
ប្រោះឈាមនោះលើព្រះពន្លា និងលើប្រដាប់
ប្រដាទាំងអស់ដែលប្រើប្រាស់ សម្រាប់គោរព
បម្រើព្រះជាម្ចាស់ដែរ។ ២២តាមវិន័យអ្វីៗស្ទើរ
តែទាំងអស់បានបរិសុទ្ធ ដោយសារឈាម
ប្រសិនបើគ្មានការបង្ហូរឈាមទេ ក៏គ្មានការ
លើកលែងទោសដែរ។

## ព្រះគ្រីស្ដជាយញ្ញបូជារំដោះបាប

២៣អ្វីៗដែលគ្រាន់តែជាតំណាង តាមគំរូនៅ
ស្ថានបរមសុខ*បានបរិសុទ្ធ* ដោយពិធីទាំង
នេះទៅហើយ ចំណង់បើគំរូផ្ទាល់ដែលស្ថិតនៅ
ស្ថានបរមសុខនោះវិញ ត្រូវតែមានយញ្ញបូជាដ៏
ប្រសើរជាងនេះទៅទៀត ទើបបានបរិសុទ្ធ។
២៤ព្រះគ្រីស្ដពុំបានយាងចូលក្នុងទីសក្ការៈសង់
ឡើងដោយស្នាដៃមនុស្ស ដែលគ្រាន់តែជា
តំណាងនៃទីសក្ការៈ ដ៏ពិតប្រាកដនោះឡើយ គឺ
ព្រះអង្គបានយាងទៅចូលក្នុងស្ថានបរមសុខតែ
ម្ដង។ ឥឡូវនេះ ព្រះអង្គស្ថិតនៅចំពោះព្រះភ័ក្ត្រ
ព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់យើង។
២៥ព្រះគ្រីស្ដពុំបានបូជាព្រះជន្មព្រះអង្គ ផ្ទាល់
ច្រើនដង ដូចលោកមហាបូជាចារ្យ*ដែលតែង
តែយកឈាមសត្វ ចូលទៅក្នុងទីសក្ការៈជារៀង
រាល់ឆ្នាំនោះឡើយ។ ២៦បើព្រះអង្គបូជាព្រះជន្ម
ច្រើនដង ព្រះអង្គមុខជាត្រូវរងទុក្ខលំបាកច្រើន
លើកច្រើនសា តាំងពីកំណើតពិភពលោកមក។
តាមពិតនៅគ្រាចុងក្រោយនេះ ព្រះអង្គបាន
យាងមកតែម្ដងគត់ ដើម្បីលុបបំបាត់បាប
ដោយព្រះអង្គបានបូជាព្រះជន្ម។២៧ មនុស្ស
លោកទាំងអស់ត្រូវស្លាប់ តែមួយដង រួចត្រូវព្រះ
ជាម្ចាស់វិនិច្ឆ័យទោស យ៉ាងណា ២៨ព្រះគ្រីស្ដ
ក៏បានថ្វាយ ព្រះជន្មរបស់ព្រះអង្គតែមួយដងធ្វើ
ជាយញ្ញបូជាដើម្បីដកបាបចេញពីមនុស្សទាំង
អស់យ៉ាងនោះដែរ។ ព្រះអង្គនឹងយាងមកម្ដង
ទៀត តែលើកនេះគ្មានទាក់ទាមអ្វីនឹងបាបទេ គឺ
ព្រះអង្គយាងមកសង្គ្រោះអស់អ្នកដែលទន្ទឹងរង់
ចាំព្រះអង្គ។

១ធម្មវិន័យ*មានតែស្រមោលនៃសម្បត្តិ
១០នៅលោកខាងមុខប៉ុណ្ណោះ គឺមិនមែនធ្វើឲ្យ
មនុស្សយើងឃើញសម្បត្តិទាំងនោះប្រត្យក្ស
ច្បាស់ទេ។ ហេតុនេះហើយបានជាវិន័យ ពុំអាច
ធ្វើឲ្យអស់អ្នកដែលចូលមកថ្វាយសក្ការបូជា
បានគ្រប់លក្ខណៈឡើយ ទោះបីគេថ្វាយយញ្ញ
បូជាដដែលៗជារៀងរាល់ឆ្នាំមិនចេះចប់មិនចេះ
ហើយក៏ដោយ។ ២ប្រសិនបើ ពួកអ្នកដែល
គោរពបម្រើព្រះជាម្ចាស់តាមរបៀបនេះ បាន
បរិសុទ្ធម្ដងជាសូរេចហើយនោះ គេមុខជាដឹងថា
ខ្លួនគ្មានជាប់បាបទៀតទេ ហើយគេក៏លែងមក
ថ្វាយយញ្ញបូជាទៀតដែរ។ ៣ក៏ប៉ុន្តែដោយការ
ថ្វាយយញ្ញបូជាទាំងនោះជារៀងរាល់ឆ្នាំ គេតែង
តែនាំគ្នារំឭកពីអំពើបាប ៤ព្រោះឈាមគោបា
និង ឈាមរបស់ពពែឈ្មោល ពុំអាចដកបាប

បានឡើយ។
៥ហេតុនេះ នៅពេលដែលព្រះគ្រីស្ដយាង
ចូលមកក្នុងពិភពលោក ព្រះអង្គមានព្រះបន្ទូល
ទៅកាន់ព្រះជាម្ចាស់ថា៖

*«ព្រះអង្គមិនចង់បានយញ្ញបូជា*
*ឬតង្វាយអ្វីទេ*
*តែព្រះអង្គបានធ្វើរូបកាយមួយឲ្យទូលបង្គំ*
*៦ ព្រះអង្គមិនសព្វព្រះហឫទ័យនឹងតង្វាយដុត*
*ឬយញ្ញបូជាសុំឲ្យរួចពីបាបឡើយ*
*៧ ដូច្នេះ ទូលបង្គំពោលថា៖ បពិត្រព្រះជាម្ចាស់*
*ឥឡូវនេះទូលបង្គំសូមមក*
*ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ*
*ស្របតាមសេចក្ដីដែលមានចែងទុក*
*ពីទូលបង្គំនៅក្នុងគម្ពីរ»*[ឈ]។

៨ជាបឋម ព្រះគ្រីស្ដមានព្រះបន្ទូលថា «
ព្រះអង្គមិនចង់បាន ហើយព្រះអង្គក៏មិនសព្វ
ព្រះហឫទ័យ នឹងយញ្ញបូជាតង្វាយផ្សេងៗ
តង្វាយដុតទាំងមូល ឬយញ្ញបូជារំដោះបាប»
ដែលគេថ្វាយទៅព្រះជាម្ចាស់ស្របតាមវិន័យដែ
រ។ ៩បន្ទាប់មកព្រះអង្គមានព្រះបន្ទូលថា«ឥឡូវ
នេះ ទូលបង្គំសូមមកធ្វើតាមព្រះហឫទ័យរបស់
ព្រះអង្គ»។ ដូច្នេះព្រះអង្គបានលុបបំបាត់របៀប
គោរពបម្រើព្រះជាម្ចាស់ ពីមុនចោល ហើយ
យករបៀបថ្មីមកតាំងជំនួសវិញ។១០ព្រះយេស៊ូ
គ្រីស្ដ ថ្វាយព្រះកាយរបស់ព្រះអង្គម្ដងជាសូរេច
តាមព្រះហឫទ័យព្រះជាម្ចាស់ហេតុនេះហើយ
បានជាព្រះអង្គប្រោសយើង ឲ្យបានវិសុទ្ធ។

១១បូជាចារ្យ*គ្រប់ៗរូបតែងតែឈរបំពេញ
មុខងាររបស់ខ្លួនជារៀងរាល់ថ្ងៃ ហើយថ្វាយ
យញ្ញបូជាដដែលៗជាញឹកញាប់ ជាយញ្ញបូជា
ដែលពុំអាចដកបាបបានជាដាច់ខាត។ ១២រីឯ
ព្រះគ្រីស្ដវិញ បន្ទាប់ពីព្រះអង្គបានថ្វាយយញ្ញ
បូជាតែមួយ ដើម្បីរំដោះបាបរួចហើយ ព្រះអង្គ
គង់នៅខាងស្ដាំព្រះជាម្ចាស់ រហូតតទៅ។
១៣ឥឡូវនេះ ព្រះអង្គរង់ចាំព្រះជាម្ចាស់បង្ក្រាប
ខ្មាំងសត្រូវរបស់ព្រះអង្គ ឲ្យចុះចូលក្រោមព្រះ
បាទាព្រះអង្គ។ ១៤ដោយសារតង្វាយតែមួយគត់
ព្រះគ្រីស្ដ ធ្វើឲ្យអស់អ្នកដែលទ្រង់បានប្រោស
ឲ្យវិសុទ្ធ*ហើយនោះបានគ្រប់លក្ខណៈរហូតត
ទៅ។ ១៥ព្រះវិញ្ញាណដ៏វិសុទ្ធ*ក៏បានបញ្ជាក់
ប្រាប់យើងដែរ គឺមុនដំបូងទ្រង់មានព្រះបន្ទូល
ថា៖

*១៦ «ព្រះអម្ចាស់មានព្រះបន្ទូលថា*
*លុះគ្រានេះកន្លងផុតទៅ យើងនឹងចង*
*សម្ព័ន្ធមេត្រីជាមួយគេដូចតទៅនេះ៖*
*យើងនឹងដាក់វិន័យទាំងប៉ុន្មានរបស់យើង*
*ក្នុងចិត្តរបស់ពួកគេ យើងនឹងចារវិន័យ*
*ទាំងនោះទុកក្នុងប្រាជ្ញារបស់ពួកគេដែរ»*។

១៧បន្ទាប់មក ព្រះវិញ្ញាណមានព្រះបន្ទូលបន្ថែម
ទៀតថា៖

*«ហើយយើងក៏មិននឹកនាពីអំពើបាប*
*និងអំពើទុច្ចរិតរបស់គេទៀតដែរ»*[ញ]។

១៨ដូច្នេះ ប្រសិនបើព្រះជាម្ចាស់លើកលែង
ទោសហើយនោះ មិនបាច់ថ្វាយតង្វាយសុំឲ្យរួច
ពីបាបទៀតឡើយ។

## ពាក្យដាស់តឿនឲ្យមានជំនឿខ្ជាប់ខ្ជួន

១៩ហេតុនេះ បងប្អូនអើយ យើងមានចិត្ត
រឹងប៉ឹងចូលមកក្នុងទីសក្ការៈ ដោយសារព្រះ
លោហិតរបស់ព្រះយេស៊ូ ២០ព្រោះព្រះអង្គបាន
បើកមាគ៌ាមួយថ្មី ជាមាគ៌ាដែលមានជីវិត ដោយ
ទ្រង់ឆ្លងកាត់វាំងនន ពោលគឺរូបកាយរបស់ព្រះ
អង្គដែលកើតមកជាមនុស្ស។ ២១ដោយយើង
មានមហាបូជាចារ្យ*មួយរូប ដែលគ្រប់គ្រងលើ
ព្រះដំណាក់ របស់ព្រះជាម្ចាស់ដូច្នេះ ២២យើង
ត្រូវនាំគ្នាចូលទៅជិតព្រះអង្គដោយចិត្តទៀង
ត្រង់ពោរពេញដោយជំនឿមាំមួន និងមានចិត្តប
រិសុទ្ធជ្រះស្រឡះពីគំនិតសៅហ្មង ព្រមទាំង
មានរូបកាយលាងដោយទឹកដ៏បរិសុទ្ធផង។ ២៣
ត្រូវរក្សាសេចក្ដីសង្ឃឹម ដែលយើងប្រកាសនោះ
ឲ្យបានខ្ជាប់ខ្ជួន កុំឲ្យរង្គើឡើយ ដ្បិតព្រះជា
ម្ចាស់មានព្រះបន្ទូលសន្យាយ៉ាងណា ទ្រង់ក៏នឹង
ធ្វើតាមយ៉ាងនោះដែរ[ដ]។ ២៤តោងយើងមើលថែ
រក្សាគ្នាទៅវិញទៅមក ដើម្បីជួយដាស់តឿនគ្នា
ឲ្យមានចិត្តស្រឡាញ់ និងប្រព្រឹត្តអំពើល្អ។
២៥ មិនត្រូវលះបង់ការប្រជុំគ្នា ដូចអ្នកខ្លះធ្លាប់ធ្វើ
នោះឡើយ ផ្ទុយទៅវិញយើងត្រូវលើកទឹកចិត្ត
គ្នាទៅវិញទៅមកឲ្យរឹតតែខ្លាំងឡើង ដោយ
ឃើញថា ថ្ងៃនៃព្រះអម្ចាស់កាន់តែជិតមកដល់
ហើយ។

២៦ក្រោយពី យើងបានស្គាល់សេចក្ដីពិត
ច្បាស់ហើយ ប្រសិនបើយើងប្រព្រឹត្តអំពើបាប
ដោយចេតនានោះ មុខជាគ្មានយញ្ញបូជាណា
អាចធ្វើឲ្យយើងរួចពីបាបបានទៀតឡើយ ២៧គឺ
មានតែភិតភ័យរង់ចាំការវិនិច្ឆ័យទោស និងរង់
ចាំភ្លើងដ៏សន្ធោសន្ធៅ ដែលចាំតែឆាបឆេះពួក
អ្នកប្រឆាំងប៉ុណ្ណោះ! ២៨នរណាម្នាក់បំពានលើ
ធម្មវិន័យរបស់លោកម៉ូសេ ហើយបើមានសាក្សី
ពីរឬបីនាក់ដឹងឮ គេមុខជាប្រហារជីវិតអ្នកនោះ
ឥតត្រាប្រណីឡើយ។ ២៩ចុះចំណង់បើអ្នក
ដែលមើលងាយព្រះបុត្រារបស់ព្រះជាម្ចាស់
ដោយបន្ថោកព្រះលោហិត នៃសម្ពន្ធមេត្រីជា
ព្រះលោហិត ដែលប្រោសឲ្យគេបានទៅជា
វិសុទ្ធ* ហើយប្រសិនបើគេត្មះតិះដៀលព្រះ
វិញ្ញាណ ប្រកបដោយព្រះហឫទ័យប្រណី
សន្ដោសនោះ សូមបងប្អូនគិតមើល៍ តើគេនឹង
ត្រូវទទួលទោស ខ្លាំងយ៉ាងណាទៅទៀត!
៣០ ដ្បិត យើងស្គាល់ព្រះជាម្ចាស់ដែលមានព្រះ
បន្ទូលថា *«ការសងសឹកស្រេចតែនៅលើយើង
គឺយើងទេតើដែលនឹងតបស្នងដល់គេ»* ហើយ
«ព្រះអម្ចាស់នឹងវិនិច្ឆ័យទោសប្រជារាស្ត្ររបស់
ព្រះអង្គ»[ឋ]។ ៣១គ្មានអ្វីគួរឲ្យភ័យខ្លាចជាងត្រូវ
ព្រះដ៏មានព្រះជន្មគង់នៅវិនិច្ឆ័យទោសឡើយ!
[ឌ]

៣២ក៏ប៉ុន្ដែ សូមនឹកចាំពីគ្រាដំបូងដែលបង
ប្អូនទើបនឹងទទួលពន្លឺពីព្រះជាម្ចាស់ថ្មីៗ។ពេល
នោះបងប្អូនបានតស៊ូយ៉ាងខ្លាំង ហើយបងប្អូនក៏
បានរងទុក្ខលំបាកជាច្រើន ៣៣ពេលខ្លះបងប្អូន
ត្រូវគេប្រមាថមើលងាយធ្វើបាបនៅមុខប្រជុំជន
និងពេលខ្លះទៀតបងប្អូនរួមទុក្ខជាមួយអ្នកដែល
ត្រូវគេធ្វើបាបដែរ។ ៣៤បងប្អូនបានរួមទុក្ខ

ជាមួយអស់អ្នក ដែលជាប់ឃុំឃាំងបងប្អូនសុខ
ចិត្ត ឲ្យគេរឹបអូសយកទ្រព្យសម្បត្តិរបស់បងប្អូន
ដោយរីករាយ ដ្បិតបងប្អូនដឹងថាបងប្អូនមាន
សម្បត្តិសួគ៌ ដែលប្រសើរជាងហើយនៅស្ថិត
ស្ថេររហូត។ ៣៥ហេតុនេះសូមបងប្អូនកុំលះបង់
ចិត្តរឹងប៉ឹង ដែលនឹងធ្វើឲ្យបងប្អូនទទួលរង្វាន់
យ៉ាងធំនោះឡើយ ៣៦គឺត្រូវមានចិត្តស៊ូទ្រាំ
ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់និង
ទទួលផល តាមព្រះបន្ទូលសន្យា

៣៧ *ដ្បិតនៅតែបន្តិចទៀត*
*គឺក្នុងពេលឆាប់ៗខាងមុខ*
*ព្រះអង្គដែលត្រូវយាងមក*
*ទ្រង់នឹងយាងមកដល់ជាមិនខាន*
*ព្រះអង្គមិនបង្អង់ឡើយ។*
៣៨ *«រីឯអ្នកសុចរិតជាកូនចៅរបស់យើងវិញ*
*គេនឹងមានជីវិតរស់ដោយសារជំនឿ*
*តែបើគេថយក្រោយ*
*យើងលែងពេញចិត្តនឹងគេហើយ»*[ឍ]។

៣៩ចំពោះយើងវិញ យើងមិនមែនជាអ្នក
ថយក្រោយ ឲ្យត្រូវវិនាសបាត់បង់នោះទេ គឺ
យើងជាអ្នកជឿ ដើម្បីសង្គ្រោះជីវិត[ណ]។

## អំពីជំនឿ

១ជំនឿ ធ្វើឲ្យយើងមានអ្វីៗដែលយើង
១១សង្ឃឹមថានឹងបាន[ត] និងធ្វើឲ្យស្គាល់ជាក់
ច្បាស់នូវអ្វីៗ ដែលយើងមើលពុំឃើញ។ ២
ព្រោះតែជំនឿហ្នឹងហើយបានជា ចាស់ៗនៅ
ជំនាន់ដើមបានទទួលកេរ្តិ៍ឈ្មោះល្អ។

៣ដោយសារជំនឿ យើងយល់ថា ព្រះបន្ទូល
របស់ព្រះជាម្ចាស់ បានបង្កើតពិភពលោកមក។
ដូច្នេះអ្វីៗដែលយើងមើលឃើញ មិនមែនកើត
ចេញមកពីអ្វីៗដែលមានរូបរាងនោះឡើយ។

៤ដោយសារជំនឿ លោកអបិលបានថ្វាយ
យញ្ញបូជាមួយទៅព្រះជាម្ចាស់ ជាយញ្ញបូជា
ប្រសើរជាងយញ្ញបូជារបស់លោកកាអ៊ីន។
ដោយសារជំនឿហ្នឹងហើយ បានជាព្រះជាម្ចាស់
ផ្ដល់សក្ខីភាពថា លោកជាមនុស្សសុចរិត។ព្រះ
អង្គគាប់ព្រះហឫទ័យ[ថ] នឹងតង្វាយរបស់លោក
ហើយដោយសារជំនឿ ទោះបីលោកអបិល
ស្លាប់បាត់ទៅហើយក្ដី ក៏លោកនៅតែមាន
ប្រសាសន៍នៅឡើយ[ទ]។

៥ដោយសារជំនឿ លោកហេណុកត្រូវព្រះ
ជាម្ចាស់លើកឡើងទៅស្ថានបរមសុខ រួចផុតពី
សេចក្ដីស្លាប់ ហើយគ្មាននរណារកលោកឃើញ
ទៀតឡើយ ព្រោះព្រះអង្គបានលើកលោក
ឡើងទៅ[ធ]។ មុនពេលព្រះអង្គលើកលោកឡើង
ទៅនោះ លោកបានទទួលសក្ខីភាពថា ព្រះជា
ម្ចាស់គាប់ព្រះហឫទ័យនឹងលោក។ ៦បើគ្មាន
ជំនឿ គ្មាននរណាអាចគាប់ព្រះហឫទ័យព្រះ
អង្គបានឡើយ។ អ្នកចូលមកជិតព្រះជាម្ចាស់
ត្រូវតែជឿថា ពិតជាមានព្រះជាម្ចាស់មែន
ហើយជឿថា ព្រះអង្គនឹងប្រទានរង្វាន់ដល់
អស់អ្នកដែលស្វែងរកព្រះអង្គ។

៧ដោយសារជំនឿ លោកណូអេបានទទួល
ដំណឹងពីព្រះជាម្ចាស់ អំពីហេតុការណ៍ដែលពុំ

ទាន់ឃើញមាននៅឡើយ លោកក៏ស្ដាប់តាម
ដោយគោរពប្រណិប័តន៍ គឺលោកបានសង់ទូក
មួយយ៉ាងធំ[ន] ដើម្បីសង្គ្រោះក្រុមគ្រួសាររបស់
លោក។ដូច្នេះ ដោយសារជំនឿលោកបានដាក់
ទោសពិភពលោក ហើយក៏បានទទួលសេចក្ដី
សុចរិតទុកជាមត៌ក គឺជាសេចក្ដីសុចរិតដែល
មកពីជំនឿ។

៨ដោយសារជំនឿ លោកអប្រាហាំស្ដាប់
បង្គាប់ព្រះជាម្ចាស់ ដែលបានត្រាស់ហៅលោក
ហើយចេញដំណើរទៅកាន់ស្រុកមួយ ដែល
លោកនឹងទទួលទុកជាមត៌ក។ លោកចេញ
ដំណើរទៅ ទាំងពុំដឹងថាត្រូវទៅណាផង។
៩ដោយសារជំនឿ លោកបានមករស់នៅជាអា
ណិកជន ក្នុងស្រុកដែលព្រះជាម្ចាស់បានសន្យា
ថានឹងប្រទានឲ្យ គឺលោកបានបោះជំរំនៅ
ជាមួយលោកអ៊ីសាក និងលោកយ៉ាកុបដែល
ត្រូវទទួលទឹកដីនោះជាមត៌ក រួមជាមួយលោក
តាមព្រះបន្ទូលសន្យាដដែល។ ១០លោកអប្រា
ហាំទន្ទឹងរង់ចាំទទួលក្រុងមួយ ដែលនឹងមាន
គ្រឹះរឹងមាំមួន ជាក្រុងដែលព្រះជាម្ចាស់បានធ្វើ
គម្រោង និង សង់ឡើង។

១១ដោយសារជំនឿ លោកស្រីសារ៉ាអាច
ទទួលសមត្ថភាព នឹងមានកូនបន្តពូជពង្សបាន
ថ្វីដ្បិតតែ គាត់មានវ័យចាស់ណាស់ហើយក៏
ដោយ ព្រោះគាត់យល់ថាបើព្រះជាម្ចាស់សន្យា
យ៉ាងណា ព្រះអង្គមុខជាធ្វើតាមយ៉ាងនោះដែ
រ។ ១២ហេតុនេះហើយបានជាមានមនុស្សច្រើន
ឥតគណនា ដូចផ្កាយនៅលើមេឃនិងគ្រាប់
ខ្សាច់នៅឆ្នេរសមុទ្រ[ប] កើតចេញមកពីមនុស្សតែ
ម្នាក់ ដែលចាស់ជិតស្លាប់ទៅហើយនោះផង។

១៣បុព្វបុរសទាំងនេះ បានស្លាប់ទៅទាំងនៅ
មានជំនឿដដែល ពួកលោកឥតបានទទួលអ្វីៗ
តាមព្រះបន្ទូលសន្យាទេតែបានឃើញ និងអប
អរទទួលពីចម្ងាយ ហើយប្រកាសទទួលស្គាល់
ថា ពួកលោកគ្រាន់តែជាជនបរទេសដែលធ្វើ
ដំណើរ[ផ] លើផែនដីនេះប៉ុណ្ណោះ។ ១៤អ្នកណា
និយាយដូច្នេះ បង្ហាញឲ្យឃើញច្បាស់ថា គេ
ស្វែងរកមាតុភូមិមួយ។ ១៥ប្រសិនបើបុព្វបុរស
ទាំងនោះនឹកស្រុកដែលលោកបានចាកចេញ
មក លោកមុខជាមានឱកាសវិលត្រឡប់ទៅវិញ
ពុំខាន។ ១៦តាមពិតពួកលោកចង់បានមាតុភូមិ
មួយដ៏ល្អប្រសើរជាង គឺមាតុភូមិនៅស្ថានបរម
សុខ*ឯណោះ។ ហេតុនេះហើយបានជាព្រះជា
ម្ចាស់មិនខ្មាស នឹងឲ្យគេហៅព្រះអង្គថា ជាព្រះ
របស់បុព្វបុរសទាំងនោះឡើយ ដ្បិតព្រះអង្គ
បានរៀបចំក្រុងមួយសម្រាប់ពួកលោករួចទៅ
ហើយ។

១៧ដោយសារជំនឿលោកអប្រាហាំបានយក
អ៊ីសាកទៅថ្វាយជាយញ្ញបូជា[ព] នៅពេលព្រះជា
ម្ចាស់ល្បងលមើលចិត្តលោក។ លោកថ្វាយកូន
តែមួយគត់របស់លោក ថ្វីដ្បិតតែ លោកបាន
ទទួលព្រះបន្ទូលសន្យា ១៨ហើយថ្វីដ្បិតតែព្រះ
ជាម្ចាស់មានព្រះបន្ទូលមកកាន់លោក ថា «អ៊ី
សាកនឹងបន្តពូជពង្សឲ្យអ្នក»[ភ] ក៏ដោយ។

១៩ លោកយល់ឃើញថា ព្រះជាម្ចាស់មានឫទ្ធា
នុភាព អាចប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ
បាន។ ហេតុនេះលោកក៏បានទទួលកូនមកវិញ
ដែលជានិមិត្តរូបមួយ។

២០ដោយសារជំនឿ លោកអ៊ីសាកបានឲ្យពរ
លោកយ៉ាកុប និងលោកអ៊ីសាវ ទុកសម្រាប់
អនាគត[ម]។

២១ដោយសារជំនឿ ពេលលោកយ៉ាកុបហៀ
បនឹងទទួលមរណភាព លោកបានឲ្យពរដល់
កូនៗរបស់លោកយ៉ូសែប ហើយលោកថ្វាយ
បង្គំព្រះជាម្ចាស់ ដោយបន្ទន់ខ្លួនលើឈើច្រត់
[យ]។

២២ដោយសារជំនឿ ពេលលោកយ៉ូសែបជិត
លាចាកលោកនេះទៅ លោកបានថ្លែងទុកថា
កូនចៅអ៊ីស្រាអែលនឹងចាកចេញពីស្រុកអេស៊ីប
ហើយលោកផ្ដាំគេឲ្យធ្វើយ៉ាងណាៗ ចំពោះ
ធាតុរបស់លោក[រ]។

២៣ដោយសារជំនឿ ពេលលោកម៉ូសេកើត
មក ឪពុកម្ដាយបានលាក់លោកទុកចំនួនបីខែ
ព្រោះឃើញទារកស្អាត ហើយគាត់មិនកោត
ខ្លាចបញ្ជារបស់ស្ដេចទេ[ល]។

២៤ដោយសារជំនឿ លុះដល់ម៉ូសេធំពេញវ័
យហើយ លោកមិនព្រមឲ្យគេហៅលោកថាជា
កូនរបស់បុត្រីព្រះចៅផារ៉ោនទេ។ ២៥លោក
សុខចិត្តស៊ូទ្រាំរងទុក្ខលំបាក រួមជាមួយប្រជារា
ស្ត្ររបស់ព្រះជាម្ចាស់ ជាជាងសប្បាយនឹងអំពើ
បាបតែមួយភ្លែត[វ]។ ២៦លោកយល់ឃើញថា
លោករងការប្រមាថមើលងាយដូចព្រះគ្រីស្ដ
ប្រសើរជាងបានទ្រព្យសម្បត្តិនានា នៅស្រុកអេ
ស៊ីប ដ្បិតលោកជាប់ចិត្តនឹងរង្វាន់ដែលនៅខាង
មុខ។ ២៧ដោយសារជំនឿ លោកបានចាក
ចេញពីស្រុកអេស៊ីប ឥតខ្លាចស្ដេចខ្ញាល់ឡើយ
ដ្បិតលោកកាន់ចិត្តរឹងប៉ឹង ហាក់បីដូចជាឃើញ
ព្រះជាម្ចាស់ ដែលមនុស្សពុំអាចមើលឃើញ។
២៨ដោយសារជំនឿ លោកបានធ្វើពិធីបុណ្យ
ចម្លង*និងប្រោះឈាម[ស] ដើម្បីកុំឲ្យមច្ចុរាជ[ហ]
បៀតបៀនកូនច្បងរបស់ជនជាតិអ៊ីស្រាអែល
បានឡើយ។

២៩ដោយសារជំនឿ ជនជាតិអ៊ីស្រាអែល
បានឆ្លងសមុទ្រក្រហមដូចដើរលើដីគោក រីឯ
ជនជាតិអេស៊ីបដែលខំឆ្លងមកដែរ ត្រូវទឹកស
មុទ្រគ្របពីលើ[ឡ]ស្លាប់អស់ទៅ។

៣០ដោយសារជំនឿ ជនជាតិអ៊ីស្រាអែលនាំ
គ្នាដើរជុំវិញក្រុងយេរីខូ ចំនួនប្រាំពីរថ្ងៃ ហើយ
កំពែងក្រុងក៏រលំអស់[អ]។

៣១ដោយសារជំនឿ នាងរ៉ាហាបជាស្ត្រី
ពេស្យាពុំបានវិនាសអន្តរាយ ជាមួយពួកអ្នក
ដែលប្រឆាំងនឹងព្រះជាម្ចាស់ឡើយ ព្រោះនាង
បានទទួលពួកអ្នកស៊ើបការណ៍ ដោយមេត្រី
ភាព[ក]។

៣២តើខ្ញុំអាចនិយាយអ្វីទៀត? ខ្ញុំគ្មានពេល
នឹងនិយាយអំពីរឿងលោកកេដូន លោកបារ៉ាក់
លោកសាំសុន លោកយ៉េបថា ព្រះបាទដាវីឌ

លោកសាមូអែល និង ព្យាការីនានាទេ។
៣៣ដោយសារជំនឿ លោកទាំងនោះបានច្បាំង
នឹងនគរផ្សេងៗ បានប្រព្រឹត្តអំពើសុចរិត បាន
ទទួលអ្វីៗ ដែលព្រះជាម្ចាស់សន្យាប្រទានឲ្យ
បានបិទមាត់សឹង្ហ ៣៤បានពន្លត់ភ្លើងដែលឆេះ
សន្ធោសន្ធៅ បានគេចផុតពីមុខដាវមានកម្លាំង
ឡើងវិញនៅពេលធ្លាក់ខ្លួនឈឺខ្លាំងពូកែ នៅ
ពេលច្បាំងធ្វើឲ្យខ្មាំងសត្រូវបាក់ទ័ព។ ៣៥ស្ត្រីៗ
បានឃើញក្រុមគ្រួសាររបស់ខ្លួនដែលស្លាប់ទៅ
ហើយនោះមានជីវិតរស់ឡើងវិញ។ អ្នកខ្លះសុខ
ចិត្តឲ្យគេធ្វើទារុណកម្ម មិនព្រមឲ្យនរណាដោះ
លែងឡើយ ដើម្បីឲ្យបានជីវិតរស់ឡើងវិញដ៏
ប្រសើរជាង។ ៣៦អ្នកខ្លះទៀតសុខចិត្តឲ្យគេ
ចំអកឡកឡឺយ ឲ្យគេវាយដំហើយថែមទាំងឲ្យ
គេដាក់ច្រវាក់ឃុំឃាំងថែមទៀតផង។ ៣៧អ្នក
ខ្លះ ត្រូវគេយកដុំថ្មគប់សម្លាប់ ត្រូវគេសម្លាប់
ដោយអារនឹងរណា ត្រូវគេសម្លាប់ដោយមុខដាវ
ត្រូវរសាត់អណ្ដែត ពីកន្លែងមួយទៅកន្លែងមួយ
មានតែស្បែកចៀម និងស្បែកពពែបិទបាំងខ្លួន
ខ្វះខាតសព្វគ្រប់ទាំងអស់ ហើយត្រូវគេជិះជាន់
សង្កត់សង្កិន ធ្វើបាប ថែមទៀតផង។
៣៨លោកីយ៍ពុំសក្ដិសមនឹងឲ្យអ្នកនោះរស់នៅ
ជាមួយឡើយ ដូច្នេះគេទៅរស់នៅតែលតោល
តាមវាលរហោស្ថាន តាមភ្នំ តាមរូងភ្នំ និងតាម
រអាងភ្នំ។ ៣៩ទោះបី អ្នកទាំងនោះទទួលសក្ខី
ភាពល្អ ព្រោះតែជំនឿរបស់ខ្លួនក្ដី ក៏គេពុំបាន
ទទួលអ្វីៗ តាមព្រះបន្ទូលសន្យាដែរ។
៤០ដោយព្រះជាម្ចាស់គ្រោងទុកថា នឹងប្រទាន
អ្វីៗដ៏ល្អប្រសើរមកយើងទ្រង់ពុំបានប្រោសអ្នក
ទាំងនោះ ឲ្យបានគ្រប់លក្ខណៈមុនយើងឡើ
យ។

## ព្រះជាម្ចាស់ជាឪពុករបស់យើង

១ដោយមានមនុស្ស ជាច្រើន ឥតគណនា
១២ធ្វើជាបន្ទាល់ ទុកឲ្យយើងយ៉ាងនេះទៅ
ហើយ យើងត្រូវលះបង់ចោលអ្វីៗទាំងអស់
ដែលជាបន្ទុកពីលើយើង និងលះបង់អំពើបាប
ដែលរឹបរួតយើងនេះចោលទៅ ហើយព្យាយាម
រត់តម្រង់ទៅមុខ តាមព្រះអម្ចាស់ដាក់ឲ្យយើងរ
ត់។ ២ត្រូវសម្លឹងមើលទៅព្រះយេស៊ូ ដែលជា
ដើមកំណើតនៃជំនឿ ហើយធ្វើឲ្យជំនឿនេះ
បានគ្រប់លក្ខណៈ។ ព្រះអង្គសុខចិត្តលះបង់
អំណរ ដែលបម្រុងទុកសម្រាប់ព្រះអង្គ ហើយ
រងទុក្ខលំបាកនៅលើឈើឆ្កាង ឥតខ្លាចខ្មាស[ខ]
សោះឡើយ។ ឥឡូវនេះ ព្រះអង្គគង់នៅខាង
ស្ដាំបល្ល័ង្ករបស់ព្រះជាម្ចាស់។
៣សូមបងប្អូនគិតពីព្រះអង្គ ដែលបានស៊ូ
ទ្រាំនឹងមនុស្សបាប ដែលប្រឆាំងព្រះអង្គយ៉ាង
ខ្លាំងនោះទៅ ដើម្បីកុំឲ្យបងប្អូនធ្លើយណាយ
បាក់ទឹកចិត្តឡើយ។ ៤បងប្អូនពុំទាន់បានតយុទ្ធ
ទល់នឹងបាប រហូតដល់ទៅបង្ហូរឈាមទេ ៥តែ
បងប្អូនបែរជាភ្លេចព្រះបន្ទូលទូន្មានរបស់ព្រះជា
ម្ចាស់មកកាន់បងប្អូន ដូចឪពុកទូន្មានកូនដែរ គឺ
ថា៖

«*កូនអើយ មិនត្រូវធ្វេសប្រហែសនឹង*
*ការវាយប្រដៅរបស់ព្រះអម្ចាស់ឡើយ*

*ហើយក៏មិនត្រូវធ្លាក់ទឹកចិត្ត*
*នៅពេលព្រះអង្គស្ដីបន្ទោសដែរ*
៦ *ដ្បិតព្រះអម្ចាស់ប្រដៅ*
*អ្នកដែលព្រះអង្គស្រឡាញ់ ហើយ*
*វាយអ្នកដែលព្រះអង្គទទួលជាកូន»។*[គ]

៧បងប្អូនស៊ូទ្រាំនឹងការប្រដៅបែបនេះ មក
ពីព្រះជាម្ចាស់រាប់បងប្អូនថាជាកូន។ តើមាន
កូនណាដែលឪពុកមិនវាយប្រដៅ? ៨ប្រសិនបើ
បងប្អូនមិនបានទទួលការវាយប្រដៅ ដូចកូន
ឯទៀតៗទទួលទេនោះ បានសេចក្ដីថាបងប្អូន
ជាកូនឥតខាន់ស្លា មិនមែនជាកូនពេញច្បាប់
ឡើយ។ ៩ក្នុងលោកនេះ យើងមានឪពុកដែល
ធ្លាប់វាយប្រដៅយើង ហើយយើងនៅតែគោរព
គាត់ដដែល។ រីឯព្រះបិតាជាម្ចាស់លើជីវិត[ឃ]
ទាំងអស់នោះវិញ យើងត្រូវស្ដាប់បង្គាប់ព្រះអង្គ
ឲ្យរឹតតែខ្លាំងទៅទៀត ដើម្បីឲ្យបានទទួលជីវិ
ត។ ១០ឪពុកយើងតែងវាយប្រដៅតែមួយរយៈ
ពេលខ្លី តាមគាត់យល់ឃើញ។ រីឯព្រះជាម្ចាស់
វិញ ព្រះអង្គវាយប្រដៅជាប្រយោជន៍ដល់យើង
ដើម្បីប្រទានឲ្យយើងបានវិសុទ្ធ*រួមជាមួយព្រះ
អង្គដែរ។ ១១ការវាយប្រដៅតែងតែធ្វើឲ្យមាន
ទុក្ខព្រួយភ្លាមៗ មិនមែនធ្វើឲ្យសប្បាយទេ។
ក្រោយមក ទើបការវាយប្រដៅផ្ដល់ឲ្យអស់អ្នក
ដែលបានទទួលការអប់រំតាមរបៀបនេះ មាន
សេចក្ដីសុខសាន្តនិងសេចក្ដីសុចរិត*ទុកជាផ
ល។ ១២ហេតុនេះ «ចូរលើកដៃដែលរួយឡើង
ហើយតម្រង់ជង្គង់ដែលទន់នោះឲ្យរឹងប៉ឹងឡើង
ដែរ»[ង]។ ១៣ត្រូវរៀបចំផ្លូវ ឲ្យបានត្រង់ ដើម្បី
ស្រួលដើរ[ច]កុំឲ្យអ្នកខូចជើងរឹតតែខូចជើងថែម
ទៀត គឺឲ្យគេបានជាវិញប្រសើរជាង។

## ត្រូវស្មោះត្រង់នឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់

១៤ចូរខិតខំឲ្យបានសុខ ជាមួយមនុស្សទាំង
អស់ព្រមទាំងខិតខំឲ្យបានវិសុទ្ធ*ទៀតផង បើ
មិនបានវិសុទ្ធទេ គ្មាននរណាអាចឃើញព្រះ
អម្ចាស់បានឡើយ។ ១៥ចូរប្រយ័ត្នប្រយែងកុំឲ្យ
បងប្អូនណាម្នាក់ឃ្លាតចេញ ពីព្រះហឫទ័យ
ប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ មិនត្រូវទុក
ឲ្យការអាស្រូវចាក់ឫស ដុះឡើងបណ្ដាលឲ្យ
កើតរឿងរ៉ាវ ហើយបំពុលចិត្តគំនិតបងប្អូនជា
ច្រើននោះឡើយ។

១៦ចូរប្រយ័ត្នប្រយែងកុំឲ្យបងប្អូនណាម្នាក់
ប្រាសចាកសីលធម៌ ឬមានចិត្តប្រមាថអ្វីៗដែល
សក្ការៈដូចលោកអេសាវបានលក់សិទ្ធិជាកូន
ច្បង ព្រោះតែចង់បានម្ហូបមួយចាននោះឲ្យ
សោះ។ ១៧បងប្អូនជ្រាបស្រាប់ហើយថា
ក្រោយមក នៅពេលគាត់ចង់ទទួលពរទុកជាម
ត៌កឪពុកបានផាត់គាត់ចោលទោះបីគាត់ខំទទូច
អង្វរសុំទាំងទឹកភ្នែកក៏ដោយក៏គាត់ពុំអាចធ្វើឲ្យ
ឪពុកដូរគំនិតបានដែរ។

១៨បងប្អូនពុំបានចូលមកជិតភ្នំមួយ[ឆ]ដែល
អាចពាល់បានជាភ្នំដែលមានភ្លើងឆេះ ដែល
មានភាពងងឹតសូន្យសុង មានខ្យល់ព្យុះនោះ
ឡើយ ១៩ហើយបងប្អូនក៏ពុំបានឮស្នូរត្រែនិងឮ

ព្រះសូរសៀងដែរ។ ពេលជនជាតិអ៊ីស្រាអែល
ឮគេបានអង្វរ សុំកុំឲ្យព្រះអង្គមានព្រះបន្ទូល
ទៀត [២០]ព្រោះគេពុំអាចទ្រាំទ្រនឹងព្រះបញ្ជានេះ
បានទេ គឺថា៖«នរណាប៉ះភ្នំនេះសូម្បីតែសត្វក៏
ដោយក៏ត្រូវតែយកដុំថ្មគប់សម្លាប់ចោលដែរ»[ជ]។
[២១]នេះជាអព្ភូតហេតុមួយគួរឲ្យស្ញែងខ្លាចណាស់
បានជាលោកម៉ូសេមានប្រសាសន៍ថា៖ «ខ្ញុំភ័យ
ខ្លាចយ៉ាងខ្លាំង ហើយក៏ញ័ររន្ធត់ទៀតផង»[ឈ]។
[២២]ផ្ទុយទៅវិញបងប្អូនចូលមកជិតភ្នំស៊ីយ៉ូន មក
ជិតក្រុងរបស់ព្រះដ៏មានព្រះជន្មរស់ គឺក្រុងយេរូ
សាឡឹមនៅស្ថានបរមសុខ ដែលមានទេវទូត*
រាប់លានរាប់កោដិ [២៣]និងមានព្រះសហគមន៍
របស់ពួករៀមច្បង ដែលមានឈ្មោះកត់ទុកនៅ
ស្ថានបរមសុខកំពុងជួបជុំគ្នា យ៉ាងអធិកអធម។
បងប្អូនចូលមកជិតព្រះជាម្ចាស់ដែលវិនិច្ឆ័យ
មនុស្សទាំងអស់ និងចូលមកជិតវិញ្ញាណក្ខន្ធ
អ្នកសុចរិតដែលបានគ្រប់លក្ខណៈ[២៤]បងប្អូន
ចូលមកជិតព្រះយេស៊ូដែលជាស្ពាននៃសម្ពន្ធ
មេត្រី*ថ្មី ហើយចូលមកជិតព្រះលោហិត
សម្រាប់ប្រោះ គឺជាព្រះលោហិតដែលទូលអង្វរ
ប្រសើរជាងលោហិតរបស់លោកអបិលទៅទៀ
ត។

[២៥]ចូរប្រយ័ត្ន! បើព្រះអង្គមានព្រះបន្ទូលមក
កាន់បងប្អូន សូមកុំបដិសេធមិនព្រមស្ដាប់នោះ
ឡើយ។ ប្រសិនបើ ពួកអ្នកដែលបដិសេធមិន
ព្រមស្ដាប់ពាក្យមនុស្សទូន្មាន គេនៅលើផែនដី
មិនអាចគេចផុតពីទោស យ៉ាងហ្នឹងទៅហើយ
ចំណង់បើយើងផ្ទាល់ បើយើងព្រងើយកន្តើយ
មិនព្រមស្ដាប់ព្រះអង្គ ដែលមានព្រះបន្ទូលមក
កាន់យើងពីស្ថានបរមសុខវិញ នោះយើងរឹតតែ
ពុំអាចគេចផុតពីទោសបានឡើយ។

[២៦]ពីដើមព្រះសូរសៀងរបស់ព្រះអង្គបានធ្វើ
ឲ្យកក្រើកផែនដី ឥឡូវនេះព្រះអង្គមានព្រះ
បន្ទូលសន្យាថា៖ «ម្ដងនេះទៀតយើងនឹងធ្វើឲ្យ
កក្រើកមិនត្រឹមតែផែនដីប៉ុណ្ណោះទេ គឺកក្រើក
ទាំងផ្ទៃមេឃផងដែរ»[ញ]។ [២៧]ពាក្យ«ម្ដងនេះ
ទៀត»បង្ហាញឲ្យឃើញច្បាស់ថា អ្វីៗដែលព្រះ
ជាម្ចាស់បង្កើតមកនឹងត្រូវកក្រើក ហើយរលាយ
សូន្យអស់ទៅ គឺមានតែអ្វីៗមិនកក្រើកប៉ុណ្ណោះ
ទេដែលនៅសល់។ [២៨]ដោយយើងបានទទួល
ព្រះរាជ្យ*មួយដែលមិនចេះកក្រើក ដូច្នេះយើង
ត្រូវតែដឹងគុណ ហើយគោរពបម្រើព្រះជាម្ចាស់
តាមរបៀប ដែលព្រះអង្គគាប់ព្រះហឫទ័យ
ដោយចិត្តគោរពប្រណិប័តន៍ និងគោរពកោត
ខ្លាចព្រះអង្គ [២៩]ដ្បិតព្រះរបស់យើងដូចជាភ្លើង
ដែលឆេះសន្ធោសន្ធៅ។

## របៀបរស់នៅ
## ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់

[១]ចូរស្រឡាញ់គ្នា ជាបងប្អូនឲ្យបានជាប់ជា
១៣ និច្ច។ [២]សូមកុំភ្លេចទទួលអ្នកដទៃយ៉ាងរាក់
ទាក់។ ដោយទទួលអ្នកដទៃដូច្នេះ អ្នកខ្លះបាន
ទទួលទេវទូតទាំងមិនដឹងខ្លួន។ [៣]ចូរគិតដល់
អស់អ្នកដែលជាប់ឃុំឃាំង ហាក់បីដូចជាបង
ប្អូននៅជាប់ឃុំឃាំងរួមជាមួយគេ ហើយគិត
ដល់អស់អ្នកដែលត្រូវគេធ្វើបាប ព្រោះបងប្អូនក៏

មានរូបកាយចេះឈឺចាប់ដូចគេដែរ។
៤សូមបងប្អូនទាំងអស់គ្នា លើកតម្លៃការរស់
នៅជាស្វាមីភរិយា គឺមិនត្រូវក្បត់ចិត្តគ្នា[ង]ឡើយ
ដ្បិតព្រះជាម្ចាស់ នឹងវិនិច្ឆ័យទោសអ្នកប្រព្រឹត្ត
អំពើប្រាសចាកសីលធម៌ និងផិតក្បត់។ ៥កុំប
ណ្តោយខ្លួន ឲ្យឈ្លក់នឹងការស្រឡាញ់ប្រាក់
ឡើយ[ច] គឺត្រូវស្កប់ចិត្តនឹងទ្រព្យសម្បត្តិដែលបង
ប្អូនមាននៅពេលនេះ ដ្បិតព្រះជាម្ចាស់មានព្រះ
បន្ទូលថា៖ «យើងនឹងមិនទុកអ្នកចោលហើយក៏
មិនបោះបង់អ្នកចោលដែរ»[ឆ]។ ៦ហេតុនេះ
ហើយបានជា យើងហ៊ាននិយាយដោយចិត្តរឹង
ប៉ឹងថា «ព្រះអម្ចាស់នឹងជួយខ្ញុំ ខ្ញុំមិនខ្លាចអ្វីឡើ
យ។ តើមនុស្សអាចធ្វើអ្វីខ្ញុំកើត?»[ជ]។

៧ចូរបងប្អូនគិតដល់អ្នកដឹកនាំបងប្អូន ដែល
បានប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យ
បងប្អូនស្តាប់។ ចូរពិចារណាមើលជីវិតរបស់
លោកទាំងនោះដែលចប់របៀបណា ហើយយក
តម្រាប់តាមជំនឿរបស់លោកទៅ។

៨ព្រះយេស៊ូគ្រីស្តមិនប្រែប្រួលឡើយ ពីដើម
សព្វថ្ងៃនិងរហូតដល់អស់កល្បជានិច្ច ព្រះអង្គ
នៅតែដដែល។ ៩សូមកុំបណ្តោយខ្លួនទៅតាម
លទ្ធិផ្សេងៗពីខាងក្រៅឡើយ គួរគប្បីតាំងចិត្ត
គំនិតឲ្យបានរឹងប៉ឹងឡើង ដោយសារព្រះហឫទ័
យប្រណីសន្តោសរបស់ព្រះជាម្ចាស់ គឺមិនមែន
រឹងប៉ឹងដោយកាន់វិន័យ ស្តីអំពីអាហារទេវិន័យ
ទាំងនោះគ្មានប្រយោជន៍ ដល់អ្នកដែលកាន់
សោះ។ ១០យើងមានអាសនៈមួយដែលពួក
បូជាចារ្យធ្វើការក្នុងព្រះពន្លា* គ្មានសិទ្ធិនឹងយក
តង្វាយពីអាសនៈនោះមកបរិភោគបានឡើយ។
១១លោកមហាបូជាចារ្យ តែងយកឈាមសត្វ
ចូលទៅថ្វាយព្រះជាម្ចាស់ក្នុងទីសក្ការៈ* ដើម្បី
សុំឲ្យរួចពីបាប រីឯសាច់សត្វនោះវិញ គេយក
ទៅដុតខាងក្រៅជំរំ។ ១២ព្រះយេស៊ូក៏ដូច្នោះដែរ
ព្រះអង្គរងទុក្ខទោសនៅខាងក្រៅទីក្រុង ដើម្បី
ប្រោសប្រជាជនឲ្យបានវិសុទ្ធ ដោយសារព្រះ
លោហិតរបស់ព្រះអង្គផ្ទាល់។ ១៣ដូច្នេះយើង
ត្រូវតែចាកចេញពីជំរំទៅរកព្រះអង្គ ទាំងស៊ូទ្រាំ
ឲ្យគេប្រមាថមើលងាយ រួមជាមួយព្រះអង្គដែរ
១៤ដ្បិតក្នុងលោកនេះ យើងគ្មានក្រុងដែលនៅ
ស្ថិតស្ថេរគង់វង្សរហូតឡើយ យើងខំស្វែងរក
ក្រុងដែលនឹងមាននៅពេលខាងមុខ នោះវិញ។
១៥ចូរយើងថ្វាយយញ្ញបូជាសម្រាប់លើកតម្កើង
ព្រះជាម្ចាស់ជានិច្ច តាមរយៈព្រះយេស៊ូ គឺជា
ពាក្យហូរចេញពីបបូរមាត់យើង ដែលប្រកាស
ព្រះនាមព្រះអង្គ។ ១៦កុំភ្លេចធ្វើទាននិងជួយគ្នា
ទៅវិញទៅមក ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័
យនឹងយញ្ញបូជាបែបនេះ។

១៧ចូរទុកចិត្តលើអ្នកដឹកនាំបងប្អូន ព្រមទាំង
ស្តាប់បង្គាប់លោកទាំងនោះទៀតផង ដ្បិតលោក
តែងតែថែរក្សាព្រលឹងបងប្អូនជានិច្ចព្រោះលោក
នឹងទទួលខុសត្រូវលើបងប្អូន នៅចំពោះព្រះភ
ក្ត្រព្រះជាម្ចាស់។ បើបងប្អូនស្តាប់បង្គាប់លោក
លោកនឹងបំពេញមុខងារនេះដោយអំណរ គឺមិន
មែនដោយថ្ងូរទេ។ប្រសិនបើពួកលោកបំពេញ
មុខងារទាំងថ្ងូរបងប្អូនមុខជាគ្មានទទួលផល

ប្រយោជន៍អ្វីឡើយ។

[១៨]សូមអធិស្ឋាន*ឲ្យយើងផង ដ្បិតយើងជឿជាក់ថា យើងមានមនសិការល្អនិងមានឆន្ទៈចង់ប្រព្រឹត្តយ៉ាងល្អត្រឹមត្រូវ ក្នុងគ្រប់កាលៈទេសៈ [១៩]ជាពិសេសខ្ញុំសូមអង្វរបងប្អូនមេត្តាអធិស្ឋានឲ្យខ្ញុំអាចវិលត្រឡប់មករកបងប្អូនវិញក្នុងពេលឆាប់ៗ។

[២០]ព្រះជាម្ចាស់ ជាប្រភពនៃសេចក្ដីសុខសាន្តបានប្រោសព្រះយេស៊ូជាព្រះអម្ចាស់នៃយើងឲ្យមានព្រះជន្មរស់ឡើងវិញ។ ព្រះគ្រីស្តជាគង្វាលដ៏ប្រសើរឧត្ដមរបស់ហ្វូងចៀម ព្រោះព្រះអង្គបានចងសម្ពន្ធមេត្រីមួយថ្មី ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ដោយសារព្រះលោហិតរបស់ព្រះអង្គ។ [២១]សូមព្រះជាម្ចាស់ប្រទានឲ្យបងប្អូនមានសមត្ថភាព នឹងប្រព្រឹត្តអំពើល្អគ្រប់យ៉ាង តាមព្រះហឫទ័យរបស់ព្រះអង្គ។ សូមព្រះអង្គសម្រេចការអ្វីដែលគាប់ព្រះហឫទ័យព្រះអង្គនៅក្នុងយើង តាមរយៈព្រះយេស៊ូគ្រីស្ត។ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ! អាម៉ែន!

[២២]បងប្អូនអើយ ខ្ញុំសូមអង្វរបងប្អូនឲ្យទទួលពាក្យទូន្មានទាំងនេះទៅ ដ្បិតខ្ញុំបានសរសេរមកបងប្អូនដោយត្រួសៗប៉ុណ្ណោះ។

[២៣]សូមជ្រាបថា លោកធីម៉ូថេជាបងប្អូនរបស់យើងបានរួចពីឃុំឃាំងហើយ។ ប្រសិនបើគាត់មកដល់ឆាប់ៗ ខ្ញុំនឹងមកជួបបងប្អូនជាមួយគាត់ដែរ។

[២៤]សូមជម្រាបសួរ អ្នកដឹកនាំទាំងអស់របស់បងប្អូន ព្រមទាំងប្រជាជនដ៏វិសុទ្ធ*ទាំងអស់ផង។ បងប្អូននៅស្រុកអ៊ីតាលីក៏សូមជម្រាបសួរមកបងប្អូនដែរ។

[២៥]សូមព្រះជាម្ចាស់ប្រណីសន្ដោសបងប្អូនទាំងអស់គ្នា។

*ក. ឃ្លាដើម«ទទួលព្រះនាមទុកជាមត៌ក»។•ខ. ទំនុកតម្កើង២.៧។ ឃ្លាដើម: «យើងហ្នឹងហើយដែលបានបង្កើតព្រះអង្គមកនៅថ្ងៃនេះ»។ពាក្យបង្កើតនេះពុំមែនមានន័យថាព្រះបិតាបានបង្កើតព្រះបុត្រាមកដូចព្រះអង្គបង្កើតអ្វីៗសព្វសារពើក្នុងលោកនេះទេ តែព្រះបុត្រាបានកើតចេញមកពីព្រះបិតាផ្ទាល់តែម្ដង។នៅជំនាន់ដើមជនជាតិអ៊ីស្រាអែលតែងប្រើទំនុកតម្កើងនេះនៅពេលអភិសេកស្ដេចមួយអង្គឲ្យឡើងគ្រងរាជ្យ។•គ. ២សាមូអែល ៧.១៤។•ឃ. ទំនុកតម្កើង៩៧.៧។•ង. ទំនុកតម្កើង១០៤.៤។ ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ជាភាសាហេប្រឺឃ្លានេះមានសរសេរថា: «ព្រះអង្គបានបង្កើតពួកទេវទូតពីខ្យល់ហើយបង្កើតពួកបម្រើរបស់ព្រះអង្គពីអណ្ដាតភ្លើង»។•ច. ឃ្លាដើម: «ដំបងរាជ្យរបស់ព្រះអង្គជាដំបងរាជ្យយុត្តិធម៌»។*

*ឆ. ទំនុកតម្កើង៤៥.៧–៨។•ជ. ទំនុកតម្កើង១០២.២៦–២៨។• ឈ. ទំនុកតម្កើង ១១០.១។*

*ញ. ឯកសារដើមខ្លះជាភាសាក្រិកមានឃ្លាបន្ថែមថា: «ព្រះអង្គបានតែងតាំងគេឲ្យត្រួតត្រាលើអ្វីៗដែលព្រះអង្គបង្កើតមក»។•ដ. ទំនុកតម្កើង៨.៥–៧។•ឋ. គឺព្រះយេស៊ូគ្រីស្ត។•ឌ. ទំនុកតម្កើង២២.២៣។•ឍ. ២សាមូអែល២២.៣; អេសាយ៨.១៧។•ណ. អេសាយ៨.១៨។*

ត. យើងអាចបកប្រែតាមរបៀបផ្សេងថា«ǹជាមហាបូជាចារ្យស្របតាមជំនឿដែលយើងប្រកាស» ឬ«ǹជាមហាបូជាចារ្យដែលយើងថាយើងជឿ»។•ថ.ឃ្លាដើម«ខ្ពស់មុខលើសេចក្ដីសង្ឃឹម»។•ទ.ឯកសារខ្លះមានឃ្លាបន្ថែមថា:ǹយ៉ាងខ្ជាប់ខ្ជួនរហូតដល់ចុងបំផុត។•ធ.ពាក្យដើម«ស្បថ»។•ន. ទំនុកតម្កើង៩៥.៧–១១។

ប.គឺជនជាតិអ៊ីស្រាអែលនៅវាលរហោស្ថាន។•ផ. កំណើតពិភពលោក(លោកុប្បត្តិ) ២.២។•ព. ឃ្លាដើមសម្រាកពីកិច្ចការ។

ភ.ទំនុកតម្កើង២.៧។សូមអានសេចក្ដីពន្យល់នៅហេប្រឺ១.៥។•ម. ទំនុកតម្កើង១១០.៤កំណើតពិភពលោក១៤.១៨–២០។

យ.ឬ«ព្រះបន្ទូលអំពីសេចក្ដីសុចរិត»។•រ. យើងអាចបកប្រែថា«មនុស្សគ្រប់លក្ខណៈ» ក៏បាន។•ល.ពាក្យដើម«កិច្ចការដែលស្លាប់»។

វ. កំណើតពិភពលោក(លោកុប្បត្តិ) ២២.១៦–១៧។•ស. ពោលគឺព្រះបន្ទូលសម្បថ និងព្រះបន្ទូលសន្យា។•ហ. កំណើតពិភពលោក(លោកុប្បត្តិ) ១៤.១៧–២០។

ឡ. ចង់សំដៅទៅលើពូជពង្សរបស់លោកលេវី។•អ.ពាក្យដើម: បម្រើទីអាសនៈ។•ក.គឺព្រះអម្ចាស់យេស៊ូគ្រីស្ដ។•ខ.ទំនុកតម្កើង១១០.៤។

គ.ទំនុកតម្កើង១១០.៤។ឯកសារខ្លះមានបន្ថែមថា«តាមរបៀបព្រះបាទមែលគីសេដែក»។•ឃ. សូមអានសេរីភាព(និក្ខមនំ) ២៥.៤០។

ង. យេរេមី៣១.៣១–៣៤។•ច. ឃ្លាដើម«ខេរូប៊ីមនៃសិរីរុងរឿង»។

ឆ. ឈ្មោះស្លឹកឈើម៉្យាងនៅមជ្ឈិមបូព៌ាដែលជនជាតិអ៊ីស្រាអែលប្រើសម្រាប់ធ្វើពិធីប្រោះទឹកលើខ្លួនឲ្យរួចពីបាប។

ជ. សេរីភាព(និក្ខមនំ) ២៤.៨។

ឈ.ទំនុកតម្កើង៤០.៧–៩។•ញ. យេរេមី៣១.៣៣–៣៤។

ដ.ឃ្លាដើម«ព្រះអង្គដែលមានព្រះបន្ទូលសន្យាទ្រង់មានព្រះហឫទ័យស្មោះត្រង់»។•ឋ. ទុតិយកថា៣២.៣៥–៣៦; លូកា១៤.១៤។•ឌ. ឃ្លាដើម«ធ្លាក់ទៅក្នុងព្រះហស្ដរបស់ព្រះដ៏មានព្រះជន្មគង់នៅ»។

ឍ. ហាបាគុក២.៣–៤។•ណ.ពាក្យដើម«ព្រលឹង»។•ត. យើងអាចបកប្រែតាមរបៀបម៉្យាងទៀតថា«ជំនឿគឺជាចិត្តជឿជាក់ថាយើងមានអ្វីៗដែលយើងសង្ឃឹមថានឹងបាន»។•ថ.ពាក្យដើម: «ព្រះជាម្ចាស់ផ្ដល់សក្ខីភាពអំពីតង្វាយរបស់លោក»។•ទ. សូមអានកំណើតពិភពលោក(លោកុប្បត្តិ)៤.៤។•ធ.កំណើតពិភពលោក(លោកុប្បត្តិ)៥.១៨–២៤។•ន. កំណើតពិភពលោក(លោកុប្បត្តិ) ៦.៥ដល់១០.៣២។

ប. កំណើតពិភពលោក(លោកុប្បត្តិ) ១៥.៥;២២.១៧។•ផ. កំណើតពិភពលោក២៣.៤។•ព. កំណើតពិភពលោក ២២។•ភ. កំណើតពិភពលោក ២១.១២។•ម.កំណើតពិភពលោក ២៧.២៨–២៩,៣៩–៤០។•យ. កំណើតពិភពលោក៤៨.១៥–១៦,៤៧.៣១។•រ. កំណើតពិភពលោក៥០.២៤–២៥។•ល. សេរីភាព(និក្ខមនំ)១.២២; ២.១–២។

វ. សេរីភាព(និក្ខមនំ)២.១១–១២។•ស. មុននឹងចាកចេញពីស្រុកអេស៊ីបលោកម៉ូសេបានបង្គាប់ឲ្យជនជាតិអ៊ីស្រាអែលសម្លាប់កូនចៀមសម្រាប់ជប់លៀងក្នុងពិធីបុណ្យចម្លង* ហើយយកឈាមរបស់កូនចៀមនោះលាបក្របទ្វារផ្ទះរបស់គេទុកជាសញ្ញាសម្គាល់កុំឲ្យមច្ចុរាជសម្លាប់កូនប្រុសច្បងរបស់ជនជាតិអ៊ីស្រាអែល។សេរីភាព១២.១២–១៣។•ហ. ទេវទូតដែលមានមុខងារប្រហារជីវិតអ្នកដែលប្រឆាំងព្រះជាម្ចាស់(សូមអាន១កូរិនថូស១០.១០ដែរ)។•ឡ.ពាក្យដើម:ត្រូវ(សមុទ្រ)លេបបាត់អស់ទៅ។សូមអាន សេរីភាព(និក្ខមនំ)១២.២២–២៩។•អ. យ៉ូស៊ូអា ៦.២០។•ក. យ៉ូស៊ូអា២.១១–១២។

ខ. យើងអាចបកប្រែឃ្លានេះម៉្យាងទៀតថា«ព្រះអង្គស៊ូរងទុក្ខលំបាកនៅលើឈើឆ្កាងឥតខ្លាចខ្មាសឡើយគឺឲ្យតែបានទទួលអំណរដែលព្រះអង្គត្រូវទទួល»។•គ. សុភាសិត៣.១១–១២។•ឃ. ពាក្យដើម«ព្រះបិតានៃវិញ្ញាណនានា»។

ង. អេសាយ ៣៥.៣, សុភាសិត ៤.២៦។•ច. ឃ្លាដើម «ត្រូវរៀបចំផ្លូវឲ្យបានត្រង់សម្រាប់ជើងរបស់អ្នករាល់គ្នា»។•ឆ. ចង់សំដៅទៅលើភ្នំស៊ីណៃជាកន្លែងដែលព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីជាមួយប្រជារាស្ត្រអ៊ីស្រាអែល។•ជ. សេរីភាព (និក្ខមនំ ១៩.១៣។•ឈ. ទុតិយកថា ៩.១៩។

ញ. ហាកាយ ២.៦។•ដ. ឃ្លាដើម «ចូរឲ្យគ្រែរបស់ស្វាមីភរិយាបានឥតសៅហ្មង»។•ឋ. យើងអាចបកប្រែជាសំរាយថា: «កុំទុកឲ្យលុយកាក់ដឹកច្រមុះបងប្អូនបានឡើយ»។•ឌ យ៉ូស៊ូអា ១.៥។•ឍ. ទំនុកតម្កើង ១១៨.៦។

ឈ្មោះអូនេស៊ីម រត់ចេញពីផ្ទះ
ហើយត្រូវទទួលទោសជាទម្ងន់តាមច្បាប់។